សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights




# បើគ្មានការផ្តន្ទាទោសគឺ គ្មានការការពារ៖

## ការឆ្លើយតបចំពោះអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា


របាយការណ៍សង្ខេប
ចេញផ្សាយ ខែធ្នូ ឆ្នាំ២០១៧

# បើគ្មានការផ្តន្ទាទោសគឺ គ្មានការការពារ៖

## ការឆ្លើយតបចំពោះអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា

របាយការណ៍សង្ខេបចេញផ្សាយ ខែធ្នូ ឆ្នាំ២០១៧

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការ ដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១៣ ខេត្តផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

### ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ

បុគ្គលិកអង្គការលីកាដូ ធ្វើការឃ្លាំមើល និងស្រាវជ្រាវលើករណីរំលោភសិទ្ធិមនុស្ស ករណីរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

### ជំនួយផ្នែកសេវាសុខភាព និងសេវាកម្មសង្គមកិច្ច

ក្រុមគ្រូពេទ្យផ្តល់សេវាសុខភាពដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់អ្នកទាំងនោះ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

### ការប្រឹក្សាផ្នែកច្បាប់ដល់ជនជាប់ឃុំ

អ្នកប្រឹក្សាផ្នែកច្បាប់ ផ្តល់ការប្រឹក្សាដល់ជនជាប់ឃុំនៅពន្ធនាគារ ដើម្បីធ្វើឲ្យប្រាកដថា ជនជាប់ឃុំទាំងនោះមានតំណាង ផ្នែកច្បាប់នៅគ្រប់ដំណាក់កាលនៃនីតិវិធីដែលពាក់ព័ន្ធ។

### ការពិគ្រោះយោបល់ផ្នែកច្បាប់

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការពិគ្រោះយោបល់ផ្នែកច្បាប់ ហើយចំពោះ ករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូន ដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

### គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និង បណ្តាញនានា

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ និងសេវាសុខភាព ព្រមទាំងជួយពង្រឹងសមត្ថភាពរបស់អ្នកទាំងនោះក្នុងការតស៊ូមតិ។

### ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍

ករណីរំលោភសិទ្ធិមនុស្ស ដែលអង្គការលីកាដូបានឃ្លាំមើល និងស្រាវជ្រាវ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារ: (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែល: contact@licadho-cambodia.org
គេហទំព័រ: www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្តីផ្តើម ទំព័រ១

វិធីសាស្ត្រ ទំព័រ២

លទ្ធផលនៃករណី ទំព័រ៣

ការផ្សះផ្សាគ្នា ទំព័រ៤




រូបភាពទំព័រមុខ៖ វត្ថុប្រើប្រាស់ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ដែលលីកាដូបានឃ្លាំមើល


ការលែងលះដោយគ្មានបណ្តឹងព្រហ្មទណ្ឌ ទំព័រ១៤

ករណីព្រហ្មទណ្ឌ ទំព័រ១៧

សេចក្តីសន្និដ្ឋាន ទំព័រ១៩

អនុសាសន៍ ទំព័រ២១

# សេចក្ដីផ្ដើម

ច្បាប់ស្ដីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ) នៅកម្ពុជា បានចូលជាធរមាន ក្នុងឆ្នាំ២០០៥[១]។ ច្បាប់នេះកំណត់អំពើហិង្សាក្នុងគ្រួសារ ដោយផ្ដល់អំណាចឱ្យអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើអន្តរាគមន៍ទៅលើករណីអំពើហិង្សាក្នុងគ្រួសារ និងផ្ដល់សិទ្ធិឱ្យតុលាការចេញដីកាការពារ ហើយថែមទាំងបានចែងថា អំពើហិង្សាក្នុងគ្រួសារគួរត្រូវដាក់ទោសផ្នែកតាមក្រមព្រហ្មទណ្ឌ។ ទោះបីជាយ៉ាងណា ការសិក្សាថ្មីៗនេះបាន បង្ហាញថា ភាគច្រើននៃស្ត្រីដែលធ្លាប់រងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ មិនទាន់ទទួលបានអត្ថប្រយោជន៍អ្វីពី កិច្ចការពារដែលមានចែងនៅក្នុងច្បាប់នេះទេ។

ការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្ដីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជា[២] ("ការសិក្សាស្រាវជ្រាវថ្នាក់ជាតិ") បានបង្ហាញថា ២១% នៃស្ត្រីអាយុចន្លោះពី ១៥ឆ្នាំ ដល់ ៦៤ឆ្នាំ ដែលធ្លាប់មានទំនាក់ទំនងជាមួយដៃគូជិតស្និទ្ធ ត្រូវបានរាយការណ៍ថា បានទទួលរងអំពើហិង្សាទាំងផ្លូវកាយនិងផ្លូវភេទផង។ ក្នុង ២១% នោះ មានស្ត្រី៤៥%ដែលមិនបានរាយការណ៍ប្រាប់ទៅនរណាសោះ។ ចំណែកឯស្ត្រីដែលបានរាយការណ៍ពីការរំលោភបំពាននោះ ភាគច្រើនគឺបានប្រាប់ទៅមិត្តភក្តិ សាច់ញាតិ ឬអ្នកជិតខាង។ មានស្ត្រី ២៤% តែប៉ុណ្ណោះ ដែលបានស្វែងរកអន្តរាគមន៍ទៅអាជ្ញាធរ ឬភ្នាក់ងាររដ្ឋ ដូចជា នគរបាល ឬថ្នាក់ដឹកនាំមូលដ្ឋាន។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១៤[៣] បានបង្ហាញថា ៣១%នៃ ស្ត្រីដែលធ្លាប់រៀបអាពាហ៍ពិពាហ៍អាយុចន្លោះពី ១៥ឆ្នាំ ដល់ ៤៩ឆ្នាំ ត្រូវបានរាយការណ៍ថា បានទទួលរងអំពើហិង្សាក្នុងគ្រួសារពីសំណាក់ស្វាមី រួមមានអំពើហិង្សាតាម ផ្លូវកាយ ផ្លូវភេទ ផ្លូវអារម្មណ៍ និងផ្នែកសេដ្ឋកិច្ចផងដែរ។ ៣៨%នៃស្ត្រីដែលបានរងអំពើហិង្សាតាមផ្លូវកាយ ឬផ្លូវភេទ មិនបានស្វែងរកអន្តរាគមន៍ឬប្រាប់ទៅអ្នកដទៃឱ្យដឹងទេ។

អំឡុងពេលចងក្រងរបាយការណ៍នេះ (២០១៤-២០១៦) សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ ("លីកាដូ") បានធ្វើការឃ្លាំមើលអំពើហិង្សាក្នុងគ្រួសារជិត ៤០០ករណី។ ចំនួនករណីទាំងអស់របស់លីកាដូ ត្រូវបានរាប់បញ្ចូលទៅក្នុងតួលេខនៃរបាយការណ៍ របស់អាជ្ញាធរមួយចំនួនផងដែរ។ លទ្ធផលនៃការស្ទង់មតិថ្នាក់ជាតិ បង្ហាញថា ករណីរបស់លីកាដូ គឺជាតួលេខតូចមួយនៃករណីអំពើហិង្សាក្នុងគ្រួសារសរុប ដែលកើតមានឡើងនៅទូទាំងប្រទេស។ លទ្ធផលករណីរបស់លីកាដូដែលទើបត្រូវបានបិទបញ្ចប់បង្ហាញថា សូម្បីតែករណីដែលមានការជួយអន្តរាគមន៍ពីភ្នាក់ងាររដ្ឋ លទ្ធផលគឺហាក់ដូចជាមិនសូវគាប់ប្រសើរ ដោយសារ៤០ភាគរយនៃករណីទាំងនោះត្រូវបានបិទបញ្ចប់ ដោយឱ្យជនរងគ្រោះបន្តរស់នៅជាមួយដៃគូដែលមានចរិតហិង្សា ហើយមានតែ ២០ភាគរយប៉ុណ្ណោះ ដែលបានបិទបញ្ចប់ដោយវិធានការព្រហ្មទណ្ឌផ្សេងៗ។

មានមូលហេតុជាច្រើន ចំពោះលទ្ធផលទាំងនេះ ដែលក្នុងនោះមានដូចជា សង្គមកម្ពុជានៅតែផ្ដល់តម្លៃសង្គមទាបសម្រាប់ស្ត្រី នៅតែផ្ដល់តម្លៃខ្ពស់ទៅលើការផ្សះផ្សាគ្នារវាងប្ដីប្រពន្ធ នៅតែមានជំនឿសាសនា នៅមានចំណុចខ្វះខាតនៅក្នុងបទបញ្ញត្តិ នីតិរដ្ឋនៅមិនទាន់រឹងមាំ និងកត្តាសេដ្ឋកិច្ចផ្សេងៗទៀត។

របាយការណ៍នេះអាចសន្និដ្ឋានបានថា ការដាក់ឱ្យប្រើច្បាប់ស្ដីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ គឺជាជំហានដំបូងដ៏សំខាន់សម្រាប់គាំទ្រស្ត្រី ដើម្បីគេចចេញពីស្ថានភាពនៃអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែប្រសិនបើបញ្ហាខាងលើមិនទាន់ត្រូវបានដោះស្រាយទេនោះ ច្បាប់នេះនឹងនៅតែមិនសូវមានប្រសិទ្ធភាពដដែល។

[១] ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥។

[២] ការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្ដីពីសុខភាពនិងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីក្នុងប្រទេសកម្ពុជាឆ្នាំ២០១៥ របស់អង្គការសុខភាពពិភពលោក អង្គការសហប្រជាជាតិដើម្បីស្ត្រី ដកស្រង់ពី http://www.wpro.who.int/mediacentre/releases/2015/vaw_full-en.pdf ។

[៣] លទ្ធផលនៃការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១៤ វិទ្យាស្ថានស្ថិតិជាតិ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល និងICFអន្តរជាតិ ឆ្នាំ២០១៥។

# វិធីសាស្ត្រ

លីកាដូ បានផ្តល់សេវាដល់ជនរងគ្រោះនៃអំពើហិង្សា ក្នុងគ្រួសារអស់រយៈពេលជាង២០ឆ្នាំមកហើយ។ សព្វថ្ងៃនេះ លីកាដូមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញនិងសាខានៅតាមខេត្តចំនួន១៣ផ្សេងទៀត ដើម្បីផ្តល់សេវាប្រឹក្សាផ្នែកច្បាប់ជំនួយសម្ភារៈនិងសេវាព្យាបាលជំងឺ ទៅតាមតម្រូវការរបស់ជនរងគ្រោះ។ ភាគច្រើននៃជនរងគ្រោះបានទាក់ទងមកលីកាដូដោយផ្ទាល់ ប៉ុន្តែករណីខ្លះ ត្រូវបានណែនាំដោយអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត និងអ្នកដទៃទៀតដែលស្គាល់លីកាដូតាមរយៈរបាយការណ៍នៅលើប្រព័ន្ធផ្សព្វផ្សាយ។

ករណីអំពើហិង្សាក្នុងគ្រួសារ ស្ទើរតែទាំងអស់ដែលលីកាដូបានឃ្លាំមើល មានជាប់ពាក់ព័ន្ធនឹងប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍រួច ឬប្តីប្រពន្ធដែលរស់នៅជាមួយគ្នាដោយមិនបានរៀបអាពាហ៍ពិពាហ៍ ហើយភាគីប្តីប្រព្រឹត្តអំពើហិង្សាលើប្រពន្ធ។តួលេខមួយចំនួននៃករណីទាំងនេះមានពាក់ព័ន្ធជាមួយនឹង សមាជិកគ្រួសារដទៃទៀត[៤]។ ស្ទើរតែគ្រប់ករណីទាំងអស់ ដែលមានការបង្ករបួសស្នាមលើជនរងគ្រោះ ជារឿយៗរួមមានការរំលោភបំពានផ្លូវភេទផងដែរ ហើយករណីមួយចំនួនតូច ការរំលោភបំពានគឺធ្វើឡើងដោយពាក្យសម្តី និងផ្លូវចិត្ត។

ដោយនេះជាផ្នែកនៃការងារ បុគ្គលិកលីកាដូបានសម្ភាសន៍ជនរងគ្រោះនិងសាក្សីនិងបានកត់ត្រារឿងហេតុនៃករណីនីមួយៗ។ ក្នុងករណីមានការស្នើពីជនរងគ្រោះ បុគ្គលិកទាំងនោះអាចជួយរៀបចំពាក្យបណ្តឹងព្រហ្មទណ្ឌដាក់ទៅស្ថាប័ននគរបាល ឬតុលាការ និងបន្តឃ្លាំមើលដំណើរការនៃករណីទាំងនោះ ក្នុងគោលបំណងធ្វើឱ្យប្រាកដថា នីតិវិធីបន្ទាប់ត្រូវបានធ្វើឡើងដើម្បីផ្តន្ទាទោសជនល្មើស។ ក្រៅពីការផ្តល់ជំនួយផ្នែក ច្បាប់ក្នុងសំណុំរឿងព្រហ្មទណ្ឌ ជារឿយៗបុគ្គលិកលីកាដូ តែងជួយសរសេរពាក្យបណ្តឹងលែងលះផងដែរ។

ប្រសិនករណីនៅបើកនៅឡើយ ព័ត៌មានទាំងអស់ដែលប្រមូលបានដោយបុគ្គលិកត្រូវរក្សាទុកក្នុងប្រព័ន្ធផ្ទុកទិន្នន័យរួមមួយ។ អំឡុងពេលករណី កំពុងដំណើរការ ព័ត៌មានទទួលបានក្រោយៗមកទៀត ត្រូវបានកត់ត្រាទុក ហើយនៅពេលករណីឈានដល់ដំណាក់កាលបិទបញ្ចប់ នឹងមានការកត់ចំណាំពីរបៀប ដែលករណីបិទបញ្ចប់។ របាយការណ៍នេះធ្វើឡើងដោយផ្អែកលើការវិភាគនៃករណីអំពើហិង្សាក្នុងគ្រួសារ ដែលលីកាដូបានចងក្រងក្នុងឆ្នាំ២០១៤ ឆ្នាំ២០១៥ និងឆ្នាំ២០១៦ ដែលទើបបានបិទបញ្ចប់ក្នុងខែកក្កដាឆ្នាំ២០១៧នេះ។ ក្រៅពីការកត់ត្រាព័ត៌មាននៃករណី អតិថិជនរបស់លីកាដូចំនួន៦នាក់ត្រូវបានសម្ភាសន៍ពីបទពិសោធន៍និងកត្តាដែលធ្វើឱ្យប៉ះពាល់ដល់ការសម្រេចចិត្តរបស់អ្នកទាំងនោះ បន្ទាប់ពីករណីទាំងនោះបានបិទបញ្ចប់។ បទពិសោធន៍ជាច្រើនឆ្នាំរបស់បុគ្គលិកកម្រិតខ្ពស់នៃលីកាដូ ដែលធ្វើការពាក់ព័ន្ធនឹងករណីអំពើហិង្សាក្នុងគ្រួសារជាច្រើន ក៏បានរួមចំណែកក្នុងការផលិតរបាយការណ៍នេះផងដែរ។

[៤] លីកាដូមិនបានឃ្លាំមើលករណីអំពើហិង្សាក្នុងគ្រួសារដែលមានជនរងគ្រោះជាបុរសទេ ដោយសារអំពើហិង្សាក្នុងគ្រួសារស្ថិតក្នុងអាណត្តិការងារនៃក្រុមអ្នកឃ្លាំមើលសិទ្ធិស្ត្រី។

# លទ្ធផលនៃករណី

ចាប់ពីដើមឆ្នាំ២០១៤ ដល់ ចុងឆ្នាំ២០១៦ លីកាដូបានឃ្លាំមើលអំពើហិង្សាក្នុងគ្រួសារចំនួន ៣៩២ករណី ដែលក្នុងនោះមាន២៣៧ករណីបានបិទបញ្ចប់[៥]។ ករណីបិទបញ្ចប់ទាំងនេះ ត្រូវបានបែងចែកជា៣ប្រភេទសំខាន់ៗ រួមមាន ១០១ករណី (៤៣%) បានបិទបញ្ចប់ដោយជនរងគ្រោះដកពាក្យបណ្ដឹង ហើយវិលត្រឡប់ទៅរស់នៅជាមួយប្ដីដែលមានចរិតហិង្សាវិញ ៦៩ករណី (២៩%) បានបិទបញ្ចប់ដោយប្ដីប្រពន្ធត្រូវរស់នៅផ្សេងគ្នា ឬលែងលះគ្នា ប៉ុន្តែ មិនមានបណ្ដឹងព្រហ្មទណ្ឌណាមួយត្រូវបានធ្វើឡើងប្រឆាំងនឹងជនល្មើសនោះទេ និង ៥៣ករណី (២២ %) ទៀត បានបិទបញ្ចប់ដោយការជំនុំជម្រះក្ដីព្រហ្មទណ្ឌ។ ចំណែក ១៤ករណី (៦%) ផ្សេងទៀត បានបិទបញ្ចប់ដោយវិធីផ្សេងៗទៀត ឧទាហរណ៍ដូចជា ជនល្មើសធ្វើអត្តឃាត។ ប្រភេទសំខាន់ៗទាំង៣ នៃករណីដែលបានបិទបញ្ចប់មានរៀបរាប់លម្អិតនៅខាងក្រោមនេះ។

**លទ្ធផលនៃការបិទបញ្ចប់ករណីអំពើហិង្សាក្នុងគ្រួសារដែល លីកាដូបានឃ្លាំមើល ឆ្នាំ២០១៤-២០១៦**




[៥] ករណីជាច្រើននៅបើកនៅឡើយដោយសារមូលហេតុផ្សេងៗ។ ករណីមួយចំនួនដោយសារភាពយឺតយ៉ាវនៃដំណើរការប្រព័ន្ធយុត្តិធម៌ ប៉ុន្តែមានករណីជាច្រើនទៀតដែលបណ្ដាលមកពីការបាត់ទំនាក់ទំនងជាមួយកូនក្ដី។ កូនក្ដីភាគច្រើនជាជនក្រីក្រនិងរស់នៅតំបន់ដាច់ស្រយាល។ អ្នកខ្លះធ្វើចំណាកស្រុកទៅធ្វើការនៅឆ្ងាយ និងអ្នកខ្លះទៀតគ្មានលទ្ធភាពទិញកាតទូរស័ព្ទសម្រាប់ទំនាក់ទំនងគ្នា។

នៅក្នុងដំណើរការ ដែលប្រពន្ធសម្រេចចិត្តដកពាក្យបណ្ដឹងប្រឆាំងនឹងស្វាមីរបស់នាង ហើយត្រឡប់ទៅរស់នៅជាមួយគ្នាវិញ ជារឿយៗត្រូវបានណែនាំដោយភាគីពាក់ព័ន្ធនិងមន្ត្រីរដ្ឋហៅថា "ការផ្សះផ្សា"។ ចំពោះករណីបិទបញ្ចប់តាមវិធីនេះដែលលីកាដូបានឃ្លាំមើល ជាធម្មតាជនរងគ្រោះបានរាយការណ៍ករណី ទៅកាន់មេភូមិឬមេឃុំ ឬ នគរបាល មុនពេលផ្សះផ្សាគ្នា។ ករណីខ្លះអ្នកទាំងនោះអាចដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌទៅព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ហើយភាគីប្ដីអាចត្រូវបានឃុំខ្លួនបន្ទាប់ពីការចោទប្រកាន់។ ជនរងគ្រោះក៏អាចដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណី ដើម្បីសុំលែងលះ នៅតុលាការផងដែរ។ ការ សម្រេចចិត្តដកពាក្យបណ្ដឹង ហើយត្រឡប់ទៅរស់នៅជាមួយប្ដីវិញ ភាគច្រើនត្រូវបានធ្វើឡើងដោយស្ត្រីរស់នៅម្នាក់ឯង ឬស្ត្រីស្ថិតនៅក្រោមឥទ្ធិពលគ្រួសារ ប៉ុន្តែមានករណីច្រើនទៀត ដែលអាជ្ញាធរទទួលបានការរាយការណ៍នោះ ជាប់ពាក់ព័ន្ធក្នុងការចរចាឱ្យប្ដី ប្រពន្ធត្រូវរ៉ូវគ្នាវិញ។ ក្នុងចំណោមជនរងគ្រោះ១០១នាក់ ដែលបានសម្រេចចិត្តដកពាក្យបណ្ដឹង ហើយត្រ ឡ ប់ទៅរស់នៅជាមួយប្ដីវិញ រួមមានការសម្រេចចិ ត្តធ្វើឡើង ដោយគ្មានកិច្ចអន្តរាគមន៍ពីមន្ត្រីរដ្ឋមាន ៣៤ករណី (៣៤%) ការផ្សះផ្សាគ្នាបន្ទាប់ពីអាជ្ញាធរភូមិ - ឃុំ បានជួយសម្របសម្រួលក្នុងការចរចាមាន១៩ករណី (១៩%) ការ ផ្សះផ្សាគ្នាបន្ទាប់ពីនគរបាលបានជួយសម្របសម្រួលក្នុងការចរចាមានចំនួន៣០ករណី (៣០%) និ ងការផ្សះផ្សាគ្នាដោយចៅក្រមអំឡុងពេលដំណើរការបណ្ដឹងលែងលះមាន២០ករណី[៦] (២០%) ។

**ការពាក់ព័ន្ធនៃមន្ត្រីសាធារណៈក្នុងដំណើរការផ្សះផ្សានៃករណីអំពើហិង្សាក្នុងគ្រួសារ**




[៦] តួលេខលើសពី១០១ដោយសារករណីខ្លះទាំងនគរបាលនិងអាជ្ញាធរមូលដ្ឋានជាប់ពាក់ព័ន្ធជាមួយគ្នា។



សាលាឃុំ

របៀបនៃការផ្សះផ្សា មានភាពស្រដៀងគ្នាពីករណីមួយទៅករណីមួយទៀត។ នៅពេលស្ត្រីម្នាក់ទាក់ទងទៅមេភូមិឬមេឃុំឬនគរបាលមូលដ្ឋាន ដើម្បីស្នើឱ្យជួយក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ការឆ្លើយតបទូទៅជាងគេគឺតែងជាការបង្អាក់ទឹកចិត្តក្នុងដំណើរការរឿងក្តី។ អាជ្ញាធរតែងជំរុញឱ្យស្ត្រីរងគ្រោះ ផ្តល់ឱកាសឱ្យប្តីរបស់នាងម្តងទៀត ឬសាកសួរប្រសិនបើនាងចង់រស់នៅម្នាក់ឯងដោយលើកឡើងពីបញ្ហាសុវត្ថិភាពសម្រាប់នាងនិងកូនជាដើម។ អាជ្ញាធរក៏ប្រហែលអាចស្តីបន្ទោស ពីឥរិយាបទរបស់នាងផងដែរដោយលើកឡើងថាអ្នកទាំងពីរគឺខុសស្មើគ្នា ហើយនាងខុសព្រោះមិនបានរៀបចំអាហារឱ្យទាន់ ពេ លវេលាឬនិយាយស្តីខ្លាំងៗ ឬមកពីព្យាយាមប្រកែកជាមួយប្តីពេកដែលនាំឱ្យគាត់ប្រើអំពើហិង្សា។ ជារឿយៗ អាជ្ញាធរតែងតែហៅភាគីប្តីមកជួបគ្នាជាមួយប្រពន្ធ ដើម្បីឱ្យភាគីទាំងពីរអាច "ចរចាគ្នា"។ ក្នុងនោះការចរចាតែងមានការរិះគន់លើកំហុសនៃភាគីទាំងពីរនៅក្នុងកិច្ចសន្យា ដែលអ្នកទាំងពីរព្រមព្រៀងថានឹងព្យាយាមកែប្រែឥរិយាបថ។

ក្នុងករណីដែលមានការចរចាពីនគរបាល ជាធម្មតាភាគីទាំងពីរត្រូវចុះហត្ថលេខា លើកិច្ចសន្យាមួយដោយសន្យាថានឹងកែប្រែចំណុចខ្វះខាតនៃ ឥរិយាបថរបស់ខ្លួន ឧទាហរណ៍ ភាគីប្រពន្ធសន្យាថានឹងឈប់ស្តីបន្ទោសឱ្យប្តី ហើយភាគីបុរសសន្យាថាឈប់ប្រើអំពើហិង្សា ឬឈប់មានទំនាក់ទំនងស្នេហាជាមួយនារីផ្សេងជាដើម។ ករណីខ្លះភាគីបុរសបានអះអាងថា គាត់នឹងទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើគាត់មិនគោរពតាមកិច្ចសន្យា។ ជាទូទៅ កិច្ចសន្យាត្រូវបានរក្សាទុកនៅប៉ុស្តិ៍នគរបាល។ ពេលខ្លះ ភាគីស្ត្រីជាអ្នកស្នើឱ្យមានការចរចាបែបនេះឡើង។ ក្នុងចំណោម៧នៃ៣០ករណីដែលបានចរចាដោយនគរបាល ជនរងគ្រោះបានប្រាប់បុគ្គលិកលីកាដូថា នាងបានសុំឱ្យនគរបាលជួយធ្វើអន្តរាគមន៍តាមវិធីនេះ។ ស្ត្រីទាំងនោះលើកឡើងពីក្តីរំពឹងទុកថា ការចូលរួមរបស់នគរបាល និងការព្រមានចាត់វិធានការក្នុងករណីមិនគោរពតាម អាចនឹងធ្វើឱ្យប្តីរបស់គាត់កែប្រែឥរិយាបថបាន។ ករណីខ្លះទៀត វិធីនេះអាចប្រើបានក្នុងរយៈពេលខ្លីប៉ុន្តែមិនអាចជោគជ័យ សម្រាប់ដំណោះស្រាយ រយៈពេលវែងទេ។ បុគ្គលិកលីកាដូ បានជួបករណីជាច្រើន ដែលប្តីប្រពន្ធ បានធ្វើកិច្ចសន្យាម្តងហើយម្តងទៀតជាមួយនគរបាល ដោយគ្មានមូលដ្ឋានច្បាប់ទេ ហើយក្រមនីតិវិធីព្រហ្មទណ្ឌ ក៏មានចែងយ៉ាង ច្បាស់ក្នុងការហាមឃាត់នគរបាល ដែលមិនចាត់វិធានការ លើរឿងក្តីដែលជនរងគ្រោះបានដកពាក្យបណ្តឹងវិញឬ ហាម ឃាត់ការចរចារកដំណោះស្រាយ រវាងជនរងគ្រោះ និងជនសង្ស័យជាដើម[៧]។ ទោះបីជាយ៉ាងនេះក្តី ការអនុវត្តនៃដំណើរការផ្សះផ្សារបស់នគរបាលបានក្លាយជាទម្លាប់ទៅហើយ។

[៧] មាត្រា៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។



ស្វាមីភរិយាមួយគូ បានរស់នៅជាមួយគ្នាអស់រយៈពេល២០ឆ្នាំ ហើយភាគីប្តីបានប្រើអំពើហិង្សាលើរូបរាងកាយប្រពន្ធជាច្រើនដង ដោយបោចសក់របស់នាងអូសឡើងជណ្តើរនិងដាល់ផ្ទៃមុខបណ្តាលឱ្យរងរបួសបែកមុខជាច្រើនថ្ងៃ។ នាងបានស្វែងរកអន្តរាគមន៍ពីមេឃុំនិងនគរបាលជាច្រើនដង ហើយអ្នកទាំងពីរក៏បានចុះហត្ថលេខាលើកិច្ចសន្យាជាមួយគ្នាច្រើនដងរួចមកហើយដែរ។ ក្រោយមកនាងត្រូវបានប្តីវាយធ្វើបាបបណ្តាលឱ្យសន្លប់ ហើយនាងត្រូវសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យអស់រយៈពេល២ថ្ងៃ។ នាងបានសម្រេចចិត្តដាក់ពាក្យបណ្តឹងលែងលះគ្នា ប៉ុន្តែមិនបានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌឡើយ ដូច្នេះហើយបានជានគរបាលមិនបានចាត់វិធានការលើប្តីរបស់នាង។ មួយរយៈក្រោយមក នាងបានផ្លាស់ប្តូរចិត្តពីការសុំលែងលះ ហើយអ្នកទាំងពីរក៏ត្រឡប់ទៅរស់នៅជាមួយគ្នាវិញ។

ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារបង្ហាញពីរបួសរបស់នាង

ករណីខ្លះ ស្ត្រីពិតជាបានដាក់ពាក្យបណ្តឹងលែងលះទៅតុលាការ ប៉ុន្តែករណីទាំងនេះ នៅតែអាចបិទបញ្ចប់ដោយប្តីប្រពន្ធផ្សះផ្សាគ្នា មានន័យថានីតិវិធីគឺស្រដៀងទៅនឹងដំណើរការនៅឃុំ-សង្កាត់ដែរ។ នៅពេលមានការដាក់ពាក្យបណ្តឹង ចៅក្រម នឹងកោះហៅប្រពន្ធ ឬពេលខ្លះកោះហៅភាគីទាំងពីរមកតុលាការ ហើយសាកសួរទៅភាគីប្រពន្ធពីអ្វីដែលនាងចង់បាន និងថាតើនាងប្រាកដចិត្ត ឬអត់ដែលចង់លែងលះគ្នា។ ក្រោយមកអាចនឹងមានការពិភាក្សាពីចំណុចទំនាស់គ្នារវាងភាគីនីមួយៗ និងចៅក្រមព្យាយាមសម្របសម្រួលឱ្យភាគីទាំងពីរ ស្រុះស្រួលគ្នាវិញ។ ប្រសិនបើឯកភាពគ្នា ចៅក្រមនឹងស្នើឱ្យប្រពន្ធដកពាក្យបណ្តឹងលែងលះនិងបិទបញ្ចប់រឿងក្តី។ រឿងនេះអាចកើតឡើង សូម្បីតែ នៅក្នុងករណីមានអំពើហិង្សាធ្ងន់ធ្ងរដែលអូសបន្លាយរយៈពេលយូរហើយក៏ដោយ។



ស្វាមីភរិយាមួយគូបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នារយៈពេល២៤ ឆ្នាំ ហើយភាគីប្តីបានប្រើអំពើហិង្សាលើប្រពន្ធជាច្រើនដង។ បន្ទាប់មកអ្នកទាំងពីរបានរស់នៅបែកគ្នាមួយរយៈ ប៉ុន្តែបានត្រូវរ៉ូវគ្នាវិញ។ នៅយប់មួយ ប្តីបានចេញទៅផឹកស្រានៅខាងក្រៅ ហើយត្រឡប់មកវិញនៅម៉ោង២រំលងអធ្រាត្រ។ ប្រពន្ធរបស់គាត់មិនបានបើកទ្វារឱ្យគាត់ចូលផ្ទះនោះទេ ដូច្នេះហើយទើបគាត់ទម្លុះទ្វារចូលក្នុងផ្ទះ ហើយយកពូថៅកាប់ប្រពន្ធចំក្បាលនិងដងខ្លួនចំនួន៦កន្លែង មុនពេលរត់គេចខ្លួន។ ដំបូងឡើយ ស្ត្រីនោះបានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ និងបណ្តឹងលែងលះ ប៉ុន្តែនៅពេលចៅក្រមកោះហៅនាងទៅតុលាការ ប្តីរបស់នាងក៏ត្រឡប់មកវិញ ហើយចៅក្រមក៏បានចរចាឱ្យអ្នកទាំងពីរផ្សះផ្សាគ្នាវិញ។ ចុងក្រោយ នាងបានដកពាក្យបណ្តឹងលែងលះនិងបណ្តឹងព្រហ្មទណ្ឌនោះទៅ។

អតិថិជននៃករណីអំពើហិង្សាក្នុងគ្រួសាររបស់លីកាដូ នៅផ្ទះរបស់នាង

នៅពេលជនរងគ្រោះដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌ ដែលដំណើរការដល់តុលាការ ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរកម្រនឹងសម្របសម្រួល ឱ្យមានការផ្សះផ្សា។ ទោះបីជាយ៉ាងណា នៅពេលហៅជនរងគ្រោះឱ្យនិយាយពីចំណុចទំនាស់ពួកគាត់តែងសួរទៅជនរងគ្រោះពីអ្វីដែលនាងចង់បាន ហើយនៅដំណាក់កាលនេះ ជារឿយៗ ជនរងគ្រោះតែងសម្រេចចិត្តដកពាក្យបណ្ដឹងដើម្បីត្រឡប់ទៅរស់នៅ ជា មួយប្ដីវិញ។ ភាគច្រើនករណីនេះ កើតឡើងដោយសារស្ត្រីគិតថា គ្មានលទ្ធភាពផ្គ ត់ផ្គង់ជីវភាពខ្លួនឯង និង គ្រួសារ ប្រសិនបើគ្មានប្ដីជួយទំនុកបម្រុង។ ប្រសិនបើប្ដីរបស់នាងត្រូវនគរបាលឃុំខ្លួនឬត្រូវឃុំខ្លួនបណ្ដោះអាសន្នក្នុងពន្ធនាគាររង់ចាំសវនាការ នាងប្រហែលជាត្រូវបង់ប្រាក់ មួយចំនួនដើម្បីជាថ្នូរឱ្យប្ដីរបស់នាង ទទួលបានការដោះ លែងមកវិញ។ ករណីខ្លះ មន្ត្រីតុលាការអះអាងថា នេះជាការពិន័យដើម្បីការពារកុំឱ្យមានអំពើហិង្សានិងកុំឱ្យខាតពេលរបស់តុលាការនិងនគរបាលនៅពេលក្រោយទៀត។

ហេតុផលនាំឱ្យស្ត្រីជ្រើសរើសយកការផ្សះផ្សា អាស្រ័យដោយកត្តាមួយចំនួន ដូចខាងក្រោម៖

## ហេតុផលគ្រួសារ

ការរៀបអាពាហ៍ពិពាហ៍ ជារឿងសំខាន់នៅកម្ពុជាជាពិសេសសម្រាប់ស្ត្រី។ ស្ត្រីដែលរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង[៨] និងខណៈពេលដែលស្ត្រីជាច្រើនបានចាប់ផ្ដើមចេញធ្វើការក្រៅផ្ទះនៅទសវត្សរ៍ចុងក្រោយនេះ តួនាទីសំខាន់ៗរបស់អ្នកទាំងនោះនៅក្នុងសង្គមគឺ នៅតែជាប្រពន្ធជាម្ដាយនិងជាស្ត្រីមេផ្ទះ។ ទោះបីជាយ៉ាងណា សង្គមកម្ពុជាបានឱ្យតម្លៃខ្ពស់ទៅលើព្រហ្មចារីរបស់ស្ត្រី ហើយការរៀបអាពាហ៍ពិពាហ៍ គឺត្រូវបាន មើលឃើញថាជាកិច្ចការពារស្ត្រីពីគ្រោះថ្នាក់លើរូបរាងកាយដែលអាចកើតមាននិងការពារកិត្តិ យ សរបស់អ្នកទាំងនោះ។ ការយល់ឃើញនេះនៅតែប ន្តសូម្បីតែការរៀបអា ពាហ៍ពិពាហ៍នោះអាចនាំឱ្យមានហានិភ័យដល់ស្ត្រីក៏ដោយ។



ស្វាមីភរិយាមួយគូបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាអស់រយៈពេលជាង២០ឆ្នាំមកហើយ។ ជុំវិញអាពា ហ៍ ពិពាហ៍នោះភាគីប្ដីតែងតែវាយធ្វើបាបប្រពន្ធរហូតដ ល់ សន្លប់ជាញឹកញាប់។ ឪពុកម្ដាយរបស់នាងតែងបញ្ចុះបញ្ចូលនាងឱ្យផ្សះផ្សាជាមួយប្ដីវិញ ហើយការផ្សះផ្សាក៏ត្រូវបានចរចាដោយអាជ្ញាធរមូលដ្ឋាន និងនគរបាលផងដែរ។ អាពាហ៍ពិពាហ៍ ត្រូវបានរៀបចំឡើងតាំងពី ប្រពន្ធនៅវ័យជំទង់ម្លេះ បន្ទាប់ពីប្ដីបច្ចុប្បន្នរបស់នាងបានរំលោភនៅយប់មួយ ខណៈពេលនាងដើរទៅបន្ទប់ទឹក។ នាងមិនចង់រៀបអាពាហ៍ពិពាហ៍ទេ ហើយតែងតែស្អប់ប្ដីរបស់នាង ប៉ុន្តែឪពុកម្ដាយរបស់នាងបានប្រាប់នាងថា មានតែការរៀបអាពាហ៍ពិពាហ៍ម៉្យាងទេ ដែលអាចការពារនាងពីការនិយាយពីមាត់មួយទៅមាត់មួយរបស់អ្នកស្រុកបាន។

អតិថិជននៃករណីអំពើហិង្សាក្នុងគ្រួសាររបស់លីកាដូ នៅផ្ទះរបស់នាង

[៨] ចំនួ នពាក់កណ្ដាលនៃ ស្ត្រីកម្ពុជាបានរៀបអាពាហ៍ពិពាហ៍នៅអាយុ២០ឆ្នាំកន្លះ។ លទ្ធផលនៃការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១៤ វិទ្យាស្ថានស្ថិតិជាតិ អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល និងICFអន្តរជាតិ ឆ្នាំ២០១៥។

មិនត្រឹមតែស្ត្រីប៉ុណ្ណោះទេ ដែលរងសម្ពាធពីគ្រួសារ និងសង្គមទូទៅក្នុងការរៀបអាពាហ៍ពិពាហ៍ ហើយទ្រាំរស់នៅក្នុងជីវិតអាពាហ៍ពិពាហ៍។ នៅកម្ពុជាគ្រួសារជាប្រភពចម្បងដែលអាចពឹងផ្អែកនៅក្នុងសង្គម ហើយសមាជិកគ្រួសារ ត្រូវបានរំពឹងថានឹងជួយបំពេញតម្រូវការគ្រួសារទាំងមូល ដើម្បីភាពសុខដុមរមនាក្នុងក្រុមគ្រួសារ។ ទោះបីជាយ៉ាងណា ក្តីរំពឹងទុកនេះគឺមានលក្ខណៈខុសគ្នាខ្លាំង ហើយបន្ទុកនៃការលះបង់ផ្ទាល់ខ្លួន ក្នុងការរក្សាតម្លៃកិត្តិយសគ្រួសារ ហាក់ដូចជាធ្លាក់ទៅលើស្ត្រីធ្ងន់ជាងគេ។ ឧទាហរណ៍ របាយការណ៍នេះមានបទសម្ភាសន៍របស់ស្ត្រីម្នាក់ដែលបានទទួលរងអំពើហិង្សាពីសំណាក់ប្តីដែលលួចមានស្នេហាជាមួយនារីផ្សេង ហើយនាងបាននិយាយថា ម្តាយក្មេករបស់នាងដែលរស់នៅជាមួយគ្នាធ្លាប់ប្រាប់នាងឱ្យអត់ធ្មត់ជាមួយប្តី ហើយមិនត្រូវរអ៊ូរទាំទេព្រោះបុរសទាំងអស់សុទ្ធតែប្រព្រឹត្តដូចគាត់ នេះជាចរិតពីធម្មជាតិរបស់អ្នកទាំងនោះ។ នេះជាទឡ្ហីករណ៍ទូទៅមួយដែលមិនត្រឹមតែឪពុកម្តាយក្មេកប៉ុណ្ណោះទេដែលនិយាយបែបនេះ ក្នុងករណីជាច្រើនទៀតនៅពេលមានអំពើហិង្សាកើតឡើង ស្ត្រីបានគេចចេញទៅរស់នៅជាមួយក្រុមគ្រួសាររបស់នាងដើម្បីសុវត្ថិភាព ប៉ុន្តែក្រុមគ្រួសារខ្លួនឯងនេះ ហើយដែលបាន បញ្ចុះបញ្ចូលនាងឱ្យត្រឡប់ទៅរស់នៅជាមួយប្តីរបស់នាងវិញ។

## ជំនឿសាសនា

ទស្សនៈដែលនិយាយថា មនុស្សម្នាក់ត្រូវតែអត់ធ្មត់ដើម្បីបញ្ចប់ជម្លោះ គឺត្រូវបានលើកឡើងជារឿយៗដោយជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ នៅកម្ពុជា ហើយទស្សនៈនេះ មានឫសគល់ ក្នុងការប្រកាន់ខ្ជាប់នៃព្រះពុទ្ធសាសនានៅក្នុងប្រទេស។ ស្ត្រីជាច្រើនបាននិយាយថា អំពើហិង្សាដែលប្រព្រឹត្តដោយប្តីរបស់ពួកគាត់ គឺមកពីភ័ព្វសំណាងមិនល្អ ឬជាកម្មដែលអ្នកទាំងនោះបានសាងកាលពីអតីតជាតិ។ ដូចនេះ ត្រូវចាត់ទុកថាជារឿងធម្មតា។ លើសពីនេះ ស្ត្រីទាំងនោះយល់ថា ការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងដៃគូដែលមានចរិតហិង្សា គឺជាការសងសឹក មិនមែនជាការស្វែងរកយុត្តិធម៌នោះទេ ដូច្នេះ ហើយការគុំគួនសងសឹកគ្នា ត្រូវបានហាមឃាត់នៅក្នុងទស្សនៈរបស់ព្រះពុទ្ធ។ ស្ត្រីម្នាក់បានផ្តល់បទសម្ភាសន៍នៅក្នុងរបាយការណ៍នេះបានពន្យល់ថា ការសងសឹក គឺជាដំណើរតតឈប់ឈរនៃអំពើហិង្សា។ នាងបានសម្រេចមិនដាក់ពាក្យប្តឹងប្តីរបស់នាង ដើម្បីការពារកុំឱ្យគាត់ប្រើអំពើហិង្សាលើរូបនាងតទៅទៀត។ នាងបានលើកឡើងពីស្ថានភាពលំបាកក្នុងពន្ធនាគារនៅកម្ពុជាថាជាគ្រោះថ្នាក់សម្រាប់ប្តី ប្រសិនបើនាងដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌដែលខុសពីអ្វីដែលនាងចង់អត់ឱនឱ្យប្តីរបស់នាង។ ក្រៅពីមិនចង់សងសឹក នាងបែរជាជឿជាក់ថានាងកំពុងតែជួយខ្លួនឯង ឱ្យរួចផុតពីការប្រើអំពើហិង្សាជាមួយប្តី នៅពេលប្តីរបស់នាង ដល់ពេលដោះលែងមកវិញ ក៏ដូចជាអំពើហិង្សាដែលអាចកើតមាននៅក្នុងជីវិត ប្រសិនបើនាងមានភ័ព្វសំណាងមិនល្អជួបប្តីរបស់នាងម្តងទៀត។

លើសពីនេះ ជំនឿអរូបី នៅតែរីករាលដាលពេញប្រទេសកម្ពុជា ហើយជំនឿទាំងពីរនេះតែងនៅជាមួយគ្នា។ មនុស្សជាច្រើនជឿថា ទង្វើរបស់មនុស្សជាទំនួលខុសត្រូវនៃវិញ្ញាណល្អនិងវិញ្ញាណអាក្រក់ ហើយអ្នកខ្លះទៀតយល់ថា អំពើហិង្សាក្នុងគ្រួសារកើតឡើងដោយសារវិញ្ញាណអាក្រក់។ ចំពោះមនុស្សដែលមានទស្សនៈបែបនេះ ការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌ គឺមិនមានន័យសម្រាប់អ្នកទាំងនោះឡើយ។ ស្ត្រីម្នាក់ដែលទទួលរងអំពើហិង្សាពីប្តីស្ទើររាល់ថ្ងៃហើយដែលបានធ្វើកិច្ចសន្យាជាមួយនគរបាលជាច្រើនផងដែរនោះ បានផ្តល់បទសម្ភាសន៍ថានាងបាននាំប្តីទៅជួបព្រះសង្ឃមួយអង្គ ព្រោះនាងជឿថាប្តីរបស់នាងត្រូវបានអំពើអាបធ្មប់ចូលសន្ធិតក្នុងខ្លួន។ មុនពេលព្រះសង្ឃដេញអំពើធ្មប់នោះចេញ ព្រះសង្ឃបានបញ្ជាក់ថា អំពើអាបធ្មប់នោះ ត្រូវបានធ្វើឡើងដោយញាតិសន្តានដែលមិនសប្បាយចិត្ត។ បន្ទាប់មកស្ត្រីនោះ បានអះអាងថា ឥរិយាបថប្តីរបស់នាងបានល្អប្រសើរជាងមុនដូច្នេះហើយអ្នកទាំងពីរក៏បន្តរស់នៅជាមួយគ្នា។ ក្រោយមកទៀត នៅពេលផ្តល់បទសម្ភាសន៍ ស្ត្រីដដែលបាននិយាយថា ប្តីរបស់នាងកំពុងមានទំនាក់ទំនងស្នេហាជាមួយនារីផ្សេង ហើយនាងបានកត់សម្គាល់ឃើញថា នារីម្នាក់នោះតែងមានស្នាមជាំនៅលើមុខ។ នាងក៏និយាយថានាងមានការសោកស្តាយដែលគ្រោះអាក្រក់ របស់នាងត្រូវធ្លាក់ទៅលើនារីម្នាក់នោះ។

## នគរបាល តុលាការ និងច្បាប់

ដូចបានរៀបរាប់ខាងលើអាជ្ញាធរមូលដ្ឋាននគរបាល និងតុលាការ មានតួនាទីសំខាន់ក្នុងការសម្របសម្រួលជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារឱ្យផ្សះផ្សាគ្នាវិញ។ នេះមិនមែនជារឿងចម្លែកទេ ពួកគាត់ជាផ្នែកមួយនៃសង្គម និងប្រកាន់ឥរិយាបថជាច្រើនក្នុងសង្គមដូចគ្នា ពាក់ព័ន្ធនឹងសារៈសំខាន់នៃភាពសុខដុមរមនានៅក្នុងសហគមន៍ និង ភាពស្រុះស្រួលគ្នាក្នុងគ្រួសារ ចំពោះមនុស្សដែលពួកគាត់បានធ្វើអន្តរាគមន៍។ ករណីភាគច្រើន នៅពេលជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារណាម្នាក់ ទៅជួបជាមួយមេឃុំ-ចៅសង្កាត់ដើម្បីប្តឹងសុំលែងលះ ដែលតែងកើតមានបន្ទាប់ពីមានការបង្ករបួសស្នាមលើរូបនាង មេឃុំ ឬចៅសង្កាត់នឹងប្រាប់នាងឱ្យទប់អារម្មណ៍កុំឆេវឆាវមួយស្របក់ ហើយគិតពីសុខុមាលភាពរបស់កូនៗ ដោយ



ប៉ុស្តិ៍នគរបាលរដ្ឋបាលនៅតំបន់ដាច់ស្រយាល

លើកឡើងថា គ្មានអ្វីល្អប្រសើរសម្រាប់កូនៗជាងឃើញឪពុកម្ដាយរស់នៅជុំគ្នាទេ ទោះបីជានៅក្នុងផ្ទះកើតមានអំពើហិង្សាក៏ដោយ។

ការនិយមផ្សះផ្សាគ្នាត្រូវបានហាមឃាត់ដោយច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារមានគោលបំណងមិនត្រឹមតែ "បង្កើតយន្តការនីត្យានុកូលដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ [និង] ការពារជនរងគ្រោះ[៩]" ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង "ថែរក្សាភាពសុខដុមរមនាក្នុង គ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ[១០]" ទៀតផង ។ ការបកស្រាយខាងលើបានបង្ហាញថាមាន ចំណុចផ្ទុយគ្នាមួយរវាងគោលបំណងទាំងពីរ ដោយសារក្នុងករណីជាច្រើន ភាពសុខដុមរមនាក្នុងគ្រួសារអាចត្រូវបានរក្សាតែក្នុងករណី ដែលជនរងគ្រោះនៃអំពើហិង្សាក្នុង គ្រួសារត្រូវបានសម្របសម្រួលឱ្យបោះបង់សិទ្ធិការពារខ្លួន របស់នាងតែប៉ុណ្ណោះ។

ចំពោះគោលបំណងរក្សាភាពសុខដុមរមនាក្នុងគ្រួសារ ត្រូវបានពិភាក្សាលម្អិតនៅក្នុងបទបញ្ញត្តិក្រោយៗលើច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដែលអនុញ្ញាតឱ្យមានការផ្សះផ្សាគ្នានៅកម្រិតមូលដ្ឋាន ប្រសិនបើភាគីពាក់ព័ន្ធចង់បាន[១១] ហើយទោះបីជាបទល្មើសស្ដែងឡើងជាអំពើហិង្សាផ្លូវចិត្ត ហិង្សាសេដ្ឋកិច្ច ឬសកម្មភាពហិង្សាក៏អាចចាត់ទុកជាបទមជ្ឈិមកម្រិតស្រាលដែរ[១២]។

យោងតាមច្បាប់កម្ពុជា បទល្មើសត្រូវបានចាត់ថ្នាក់ជាបីប្រភេទគឺ បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ ដោយផ្អែកលើរយៈពេលនៃការផ្ដន្ទាទោសជាប់ពន្ធនាគារ[១៣] ប៉ុន្តែមិនបានវែកញែករវាងបទមជ្ឈិមកម្រិតធ្ងន់ និងបទមជ្ឈិមកម្រិតស្រាលនោះទេ។ នេះមានន័យថា ការសម្រេចថាតើជាបទមជ្ឈិមកម្រិតស្រាល ឬធ្ងន់ ឬក៏ថាតើអាចមានការផ្សះផ្សា ឬអត់ អាចធ្វើឡើងនៅកម្រិតមូលដ្ឋាននិងដោយមិនត្រឹមត្រូវ។ នេះក៏មានន័យថា ករណីមួយចំនួនត្រូវបានរំលោភបំពានជាយូរមកហើយ ប៉ុន្តែនៅពេលដែលគ្មានការផ្ដន្ទាទោសពីបទឧក្រិដ្ឋ ករណីទាំងនេះជារឿយៗត្រូវបិទបញ្ចប់ដោយប្ដីប្រពន្ធផ្សះផ្សាគ្នាវិញ។ ក្រៅពីអនុញ្ញាតឱ្យមានការផ្សះផ្សាគ្នានៅកម្រិតមូលដ្ឋាន ច្បាប់នេះក៏បានផ្ដល់សិទ្ធិដល់តុលាការ ដើម្បីសម្របសម្រួលឱ្យប្ដីប្រពន្ធផ្សះផ្សាគ្នា ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើភាគីទាំងពីរចង់បាន[១៤]។ បទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីស្ដីពីការលែងលះ

[៩] មាត្រា១ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥។
[១០] មាត្រាដូចគ្នាខាងលើ។
[១១] មាត្រា២៦ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥។
[១២] មាត្រាដូចគ្នាខាងលើ។
[១៣] មាត្រា៤៦ មាត្រា៤៧ និងមាត្រា៤៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។
[១៤] មាត្រា២៧ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥។ នេះហាក់ដូចជាអនុវត្តទៅលើគ្រប់ករណីរួមទាំងបទឧក្រិដ្ឋ ទោះបីជាច្បាប់មិនបានចែងច្បាស់លើចំណុចនេះក៏ដោយ។



ទ្រព្យសម្បត្តិដែលត្រូវបានបំផ្លាញក្នុងហេតុការណ៍អំពើហិង្សាក្នុងគ្រួសារ

ក៏បានអនុញ្ញាតឱ្យមានការផ្សះផ្សា នៅកម្រិតមូលដ្ឋាន[១៥] និងការផ្សះផ្សាដោយតុលាការផងដែរ[១៦]។ ការផ្សះផ្សាត្រូវបានអនុញ្ញាត ទោះបីជាភាគីមួយចង់ទាមទារលែងលះគ្នាខ្លាំងយ៉ាងណាក៏ដោយ។

ចំណុចខ្វះខាតនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ធ្វើឱ្យប្រព័ន្ធយុត្តិធម៌នៅកម្ពុជាកាន់តែចុះខ្សោយថែមទៀត។ អាជ្ញាធរមូលដ្ឋាននិងនគរបាលគឺនៅខ្វះខាតធនធាន ខ្វះខាតការបណ្តុះបណ្តាល ហើយជាទូទៅមិនសូវបានយល់ច្បាស់ពីច្បាប់។ ហេតុនេះហើយទើបពួកគាត់មិនអាចស៊ើបអង្កេតរឿងក្តី ឬប្រើច្បាប់ឱ្យបានសមស្រប ដើម្បីរកដំណោះស្រាយតាមផ្លូវតុលាការសំរាប់ជនរងគ្រោះ។ ឧទាហរណ៍ នគរបាលនៅតំបន់ជនបទជាធម្មតាតែងតែរអ៊ូរទាំដាក់ជនរងគ្រោះថា ពួកគាត់គ្មានលុយទិញប្រេងសាំងដើម្បីធ្វើដំណើរទៅដល់ផ្ទះជនរងគ្រោះ ឬចាប់ខ្លួនបុគ្គលដែលបានប្រើអំពើហិង្សានោះទេ។ ពួកគាត់ក៏មានមធ្យោបាយតិចតួចមែនទែនក្នុងការជួយផ្គត់ផ្គង់ជនរងគ្រោះ ប្រសិនបើជនរងគ្រោះពិតជាចង់រស់នៅបែកគ្នា ជាមួយប្តីមែន។ នៅក្នុងកាលៈទេសៈនេះ អាជ្ញាធរមូលដ្ឋាន រឹតតែងាយស្រួល ចំណេញពេលវេលានិងចំណាយប្រាក់ តិច ប្រសិនបើពួកគាត់ សម្របសម្រួលឱ្យប្តីប្រពន្ធផ្សះផ្សាគ្នាវិញ។

ក្នុងករណីខ្លះ នៅពេលជនសង្ស័យមានឋានៈធំជាងតំណាងអាជ្ញាធរមូលដ្ឋាន ឬមានអំណាចខ្លាំង អាជ្ញាធរមូលដ្ឋានមិនហ៊ានអនុវត្តច្បាប់នោះទេ ទោះបីជាពួកគាត់ចង់អនុវត្តក៏ដោយ។ មានករណីមួយ ស្ត្រីម្នាក់ត្រូវបានប្តីជាទាហានវាយធ្វើបាបជាញឹក ញា ប់។ នាងបានព្យាយាមប្រាប់ទៅប្រធានអ ង្គភាពរបស់ ប្តីនាង ប៉ុន្តែគាត់មិនបានជួយនាងទេ ហើយក៏បានឱ្យនាងទៅជួបនឹងមេឃុំ។ មេឃុំពិតជាមានការភ័ យខ្លាចក្នុង ការចាត់វិធាន ការ ព្រោះគាត់ដឹងថាប្តីរបស់ជនរងគ្រោះមានកាំភ្លើង ដូច្នេះគាត់បានជូនជនរងគ្រោះ មកការិយាល័យលីកាដូ ហើយលីកាដូ ក៏បានជួយនាងដាក់ពាក្យបណ្តឹងលែងលះគ្នា។ ករណីមួយទៀត ជនរងគ្រោះត្រូវបានប្តីជាទាហានវាយធ្វើបាបច្រើនដង និងគំរាមសម្លាប់ដោ យភ្ជង់នឹង កាំ ភ្លើងជាដើម។ ជ នរងគ្រោះបានដាក់ពា ក្យបណ្តឹងព្រ ហ្ម ទណ្ឌ ហើយភាគីទាំងពីរត្រូវបានចៅ ក្រ ម ស៊ើ ប សួ រកោះហៅទៅសាកសួ រ ។ ភាគីប្តីបានមកតុលា ការ រួម ជាមួយ រថយន្តមួយគ្រឿង ដែលដឹកទាហានពេញ ដោយរង់ចាំនៅខាងក្រៅតុលាការ អំឡុងពេល សា ក សួ រ ។ ចៅ ក្រ ម ស៊ើបសួរបានបញ្ចុះបញ្ចូលជនរងគ្រោះឱ្យដកពាក្យបណ្តឹង ហើយផ្សះផ្សាគ្នាជាមួយប្តីវិញ។ ក្រោយមក ចៅក្រមក៏បាន បិទបញ្ចប់ករណីនោះ[១៧]។

---

[១៥] មាត្រា៩៨២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
[១៦] មាត្រា៩៨៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
[១៧] ក រ ណី ត្រូ វ បា នបើកតាំង ពីឆ្នាំ២០១៣ មុនរយៈពេលស្រាវជ្រាវនៃរបាយការណ៍នៅចន្លោះឆ្នាំ២០១៤ដល់ឆ្នាំ២០១៦ ប៉ុន្តែករណីនេះត្រូវបានដាក់បញ្ចូលដោយសារជារឿងគួរឱ្យកត់សម្គាល់ជាខ្លាំង។

ភាពទន់ខ្សោយនៃប្រព័ន្ធយុត្តិធម៌បានបង្កើនឱ្យមានការ ប្រើ ប្រាស់ដំណើរការផ្សះផ្សាក្រៅផ្លូវការ កាន់តែច្រើនតាមម ធ្យោបាយផ្សេងៗ ដោយសារការបាត់បង់ទំនុកចិត្តនៃប្រព័ន្ធយុត្តិធម៌ ដែលធ្វើឱ្យមនុស្សជាច្រើនមានការស្ទើរស្ទាក់ក្នុងការដោះស្រាយបញ្ហាតាមផ្លូវច្បាប់។ រឿងនេះត្រូវបានដឹងយ៉ាងទូលំទូលាយថា នគរបាលនៅខ្វះខាតជំនាញ និងធនធាន ហេតុដូច្នេះហើយទើបអ្នកទាំងនោះអាចទារប្រាក់ពីជនរងគ្រោះមុនពេលដំណើរការរឿងក្តី។ រឿងនេះដូចគ្នាផងដែរនៅតុលាការ។ អំពើពុករលុយក្នុងស្ថាប័នតុលាការគឺនៅតែជាបញ្ហា ហើយមនុស្សភាគច្រើនដឹងថាដំណើរការរឿងក្តីនៅតុលាការត្រូវចំណាយពេលយូរចំណាយថវិកាច្រើនទាំងផ្លូវការនិងក្រៅផ្លូវការ ហើយអាចនឹងមិនទទួលបាន នូវអត្ថប្រយោជន៍អ្វីសោះទៀតផង[១៨]។ បើបានដឹងពីរឿងនេះគឺអាចសម្រេចចិត្តជ្រើសរើសយកដំណោះស្រាយសមស្របក្រៅប្រព័ន្ធយុត្តិធម៌ ទោះបីជាមិនសូវពេញចិត្តក៏ដោយ។ ឧទាហរណ៍ ប្រសិនបើស្ត្រីម្នាក់បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយនាងសម្រេចចិត្តថាអ្វីគ្រប់យ៉ាងដែលនាងចង់បានគឺការលែងលះដោយមិនចាំបាច់ឆ្លងកាត់បណ្តឹងព្រហ្មទណ្ឌ ប៉ុន្តែនាងមានតែវិធីម៉្យាងគត់គឺទៅតុលាការ។ នាងទំនងជាទៅជួបនឹងមេឃុំ-ចៅសង្កាត់ ដោយសាររឿងនេះមានលក្ខណៈស្មុគស្មាញ និងចំណាយថវិកាច្រើន ប៉ុន្តែយ៉ាងណា មេឃុំ-ចៅសង្កាត់គ្មានអំណាចក្នុងការសម្រេចលើករណីលែងលះគ្នានោះទេ ហើយអាចជួយឱ្យផ្សះផ្សាគ្នាតែប៉ុណ្ណោះ។

## ថវិកា និងធនធាន

កត្តាមួយដែលជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់ស្ត្រីថាតើគួរផ្សះផ្សាជាមួយប្តី ឬមិនគួរ គឺប្រភពប្រាក់ចំណូល។ ក្នុងករណីស្ទើរតែទាំងអស់ដែលលីកាដូបានឃ្លាំមើល ប្តីប្រពន្ធគឺមានភាពក្រីក្រឬក្រីក្រខ្លាំង ហើយប្រភពប្រាក់ចំណូល ពឹងផ្អែកលើមនុស្សពេញវ័យយ៉ាងតិចពីរនាក់ ដើម្បីអាចផ្គត់ផ្គង់ជីវភាពនិងការចំណាយផ្សេងៗក៏ដូចជាការមើលថែកូនៗជាដើម។ នៅកម្ពុជាគ្មានប្រព័ន្ធសន្តិសុខសង្គមផ្តល់ដោយរដ្ឋនោះទេ គឺមានតែអង្គការពីរបីប៉ុណ្ណោះ ដែលអាចផ្តល់ជម្រកសុវត្ថិភាពបណ្តោះអាសន្នសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ដោយសារមិនមានបទបញ្ញត្តិ ស្តីពីការជួយស្ត្រីឱ្យរួចផុតពីស្ថានភាពហិង្សា។ ដូច្នេះ នេះជារឿងដែលពិបាកសម្រាប់ស្ត្រីក្នុងការសម្រេចចិត្ត។ ជារឿយៗ អាជ្ញាធរមូលដ្ឋានតែងរំលឹកស្ត្រីពីរឿងនេះ នៅពេលដែលពួកគាត់ចង់លួងលោមស្ត្រីធ្វើការផ្សះផ្សាគ្នាជាមួយប្តីវិញ។

សម្ពាធផ្នែកហិរញ្ញវត្ថុ ក៏អាចត្រូវបានប្រើប្រាស់ជាមធ្យោបាយផ្សេងៗ។ នៅកម្ពុជា ការបង់ប្រាក់បណ្ណាការ (ពីគ្រួសារប្តីទៅគ្រួសារប្រពន្ធ) នៅតែជាការអនុវត្តជាទូទៅមួយ ហើយប្រាក់នេះអាចត្រូវបានប្រើប្រាស់ជាឥទ្ធិពលក្នុងការហាមឃាត់ស្ត្រីមិនឱ្យចាកចេញពីប្តី។ មានករណីមួយដែលប្តីបានវាយធ្វើបាបប្រពន្ធ ហើយបានយកកាំបិតគំរាមម្តាយក្មេកនិងប្រពន្ធទៀតផង ពេលនោះប្រពន្ធបានដាក់ពាក្យបណ្តឹងលែងលះគ្នាទៅតុលាការ ប៉ុន្តែក្រោយមកនាងបានដកពាក្យបណ្តឹង និងសម្រេចចិត្តបន្តរស់នៅជាមួយប្តីវិញ បន្ទាប់ពីប្តីទាមទារថ្លៃបណ្ណាការចំនួន ១,៧៥០ ដុល្លារវិញ ដែលនាងគ្មានលទ្ធភាពបង់ឱ្យ។

---

[១៨] របាយការណ៍របស់លីកាដូស្តីពី ការរួចខ្លួនពីបទល្មើស៖ ការអនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈ ក្នុងប្រព័ន្ធតុលាការកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១៥ ដកស្រង់ពី https://www.licadho-cambodia.org/reports/files/210kLICADHOReport-GettingAwayWithRape2015Khmer.pdf ។

ស្ត្រីម្នាក់ត្រូវបានប្តីវាយធ្វើបាបនិងទាត់ធាក់ជារឿយៗ។ ប្តីរបស់នាងបានប្រើប្រាស់ថ្នាំញៀន ហើយតែងតែចោទនាងថា មានទំនាក់ទំនងស្នេហាជាមួយប្រុសផ្សេង។នាងបានដាក់ពាក្យបណ្តឹងទៅនគរបាលជាច្រើនដង ហើយព្រមទាំងបានធ្វើកិច្ចសន្យាជាមួយប្តីជាច្រើនដងហើយដែរ។ ចុងក្រោយ នាងបានសម្រេចចិត្តបែកផ្លូវគ្នាជាមួយប្តី និងស្នើឱ្យលីកាដូជួយដាក់ពាក្យបណ្តឹងលែងលះគ្នា។នាងមិនចង់ដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌទេ។ លីកាដូបានណែនាំនាងទៅអង្គការមួយដែលអាចផ្តល់ជម្រកបណ្តោះអាសន្នដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែនាងមិនអាចយកកូនប្រុសទៅនៅជាមួយទេ ដោយសារអង្គការនោះមិនទទួលយកអ្នកស្នាក់នៅជាបុរស។ ដូច្នេះហើយ នាងបានសម្រេចចិត្តត្រឡប់ទៅផ្ទះនិងដកពាក្យបណ្តឹងលែងលះវិញដោយសារគ្មានជម្រើស។




ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ និងកូនរបស់នាង

# ការលែងលះដោយគ្មានបណ្តឹងព្រហ្មទណ្ឌ

ក្នុងចំណោមករណីជាច្រើនរបស់លីកាដូដែលបានប្រើប្រាស់ជាមូលដ្ឋាន ក្នុងការផលិតរបាយការណ៍នេះ មាន៦៩ករណី (២៩%) ត្រូវបានបិទបញ្ចប់ដោយការរស់នៅបែកគ្នាឬការលែងលះគ្នា ប៉ុន្តែគ្មានការចោទប្រកាន់ពីបទព្រហ្មទណ្ឌទេ។ ដូចបានរៀបរាប់ខាងលើ មានករណីជាច្រើនដែលចាប់ផ្តើមដោយស្ត្រីចង់លែងលះ ប៉ុន្តែបិទបញ្ចប់ដោយប្តីប្រពន្ធផ្សះផ្សាគ្នាវិញ។ ទោះបីជាយ៉ាងណាលីកាដូ ឃើញករណីមួយចំនួនដែលមេឃុំ-ចៅសង្កាត់គាំទ្រការសម្រេចចិត្តរបស់ភាគីប្រពន្ធ ឱ្យចាកចេញពីប្តី ហើយពេលខ្លះមេឃុំ-ចៅសង្កាត់ ជាអ្នកណែនាំករណីនោះមកលីកាដូ ដើម្បីទទួលបានការប្រឹក្សាផ្នែកច្បាប់។ ករណីទាំងនេះភាគច្រើនជាករណីអំពើហិង្សាដដែលៗ ឬ ករណីដែលប្តីជាមនុស្សប្រមឹកនិងមិនជួយរកប្រាក់ផ្គត់ផ្គង់គ្រួសារ។

ជាទូទៅ ការលែងលះធ្វើឡើងនៅឃុំ-សង្កាត់ និងពេលខ្លះនៅតុលាការ។ ចំពោះប្តីប្រពន្ធដែលគ្រាន់តែរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ដោយគ្មានសំបុត្រអាពាហ៍ពិពាហ៍ ការលែងលះដោយមិនប្រើច្បាប់អាចធ្វើទៅបានដោយមិនចាំបាច់ទៅតុលាការ។ជាធម្មតាប្តីប្រពន្ធទៅជួបមេឃុំចៅសង្កាត់ដើម្បីធ្វើលិខិតលែងលះ ហើយប្រសិនបើប្តីប្រពន្ធមានកូនឬទ្រព្យសម្បត្តិ មេឃុំ-ចៅសង្កាត់អាចនឹងចូលរួមចរចាក្នុងការបែងចែកទ្រព្យសម្បត្តិ និងការថែទាំកូន។ ក្នុងករណីមានសំបុត្រអាពាហ៍ពិពាហ៍ ឬការចរចាលើរឿងបែងចែកកូន និងទ្រព្យសម្បត្តិ មិនបានជោគជ័យនៅមូលដ្ឋានទេ ប្តីប្រពន្ធត្រូវទៅតុលាការដើម្បីធ្វើការលែងលះគ្នាតាមផ្លូវច្បាប់ ឬទទួលសាលក្រមពីតុលាការក្នុងការបែងចែកទ្រព្យសម្បត្តិនិងការថែទាំកូន។

ករណីខ្លះដែលបិទបញ្ចប់ដោយការលែងលះគ្នា បណ្តឹងព្រហ្មទណ្ឌត្រូវបានលើកឡើង (មើលចំណុចបន្ទាប់) ប៉ុន្តែភាគច្រើនជនរងគ្រោះមិនដែលដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌទេ ឬបានប្តឹងប៉ុន្តែក្រោយមកដកពាក្យបណ្តឹងវិញ។ មានហេតុផលមួយចំនួនចំពោះករណី នេះ។ ហេតុផលទីមួយ គឺទាំងអាជ្ញាធរមូលដ្ឋាន និង នគរបាល មិនបានលើកទឹកចិត្តឱ្យស្ត្រីដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌនោះទេឬមិនបានរាយការណ៍ករណី ទៅព្រះរាជអាជ្ញាទោះបីជា នេះជាកាតព្វកិច្ចតាមផ្លូវច្បាប់របស់ពួកគាត់ក៏ដោយ [១៩]។ ហេតុផលសំខាន់មួយ គឺពួកគាត់មិនបានចាត់ទុកអំពើហិង្សាក្នុងគ្រួសារ ជាបទល្មើសព្រហ្មទណ្ឌទេ ប៉ុន្តែចាត់ទុកជាជម្លោះឯកជន ដែលគួរតែដោះស្រាយនៅក្នុងគ្រួសារដោយខ្លួនឯង។ នគរបាលជារឿយៗតែងប្រាប់ទៅជនរងគ្រោះ ដែលចង់រាយការណ៍ពីករណីអំពើហិង្សាក្នុងគ្រួសារថា នេះមិនមែនជារឿងដែលពួកគាត់អាចជួយបានទេ ដូច្នេះហើយជនរងគ្រោះគួរតែទៅផ្ទះ និងផ្សះផ្សាគ្នាជាមួយប្តីវិញ។ នេះជាអ្វីដែលបុគ្គលិកលីកាដូបានកត់សម្គាល់ជាញឹកញាប់នៅពេលជូនជនរងគ្រោះទៅប៉ុស្តិ៍នគរបាល។

សូម្បីករណីអំពើហិង្សដែលក្នុងនោះមានការរំលោភសេពសន្ថវៈរឿង ដែលកើតឡើងក្នុងជីវិតអាពាហ៍ពិពាហ៍នេះហាក់ដូចជាជនល្មើសតែងតែរួចខ្លួនជានិច្ច។ ករណី៣ក្នុងចំណោមករណីជាច្រើន ដែលបានបិទបញ្ចប់ដោយការលែងលះគ្នា ជនរងគ្រោះបានរាយការណ៍ថា នាងត្រូវបានប្តីរំលោភជាច្រើនដង។ ករណីទាំង៣នេះ ប្តីប្រពន្ធគ្មានសំបុត្រអាពាហ៍ពិពាហ៍ទេ ហើយការរស់នៅបែកគ្នាគឺត្រូវបានចរចា ដោយមេឃុំចៅសង្កាត់។ ពេលនោះ មេឃុំ-ចៅសង្កាត់ មិនបានរាយការណ៍ពីអំពើរំលោភសេពសន្ថវៈទៅនគរបាលទេ។ អត្ថន័យនៃអំពើរំលោភសេពសន្ថវៈក្នុងក្រមព្រហ្មទណ្ឌ មិនបានដកចេញអំពើរំលោភសេពសន្ថវៈក្នុងជីវិតអាពាហ៍ពិពាហ៍ទេ ហើយរឿងនេះគួរត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ និងត្រូវផ្តន្ទាទោស យោងតាមបទបញ្ញត្តិពាក់ព័ន្ធទាំងនោះ[២០]។ ទោះបីជាយ៉ាងណា ការឱ្យអត្ថន័យនៃអំពើនេះ មិនបានចែងច្បាស់ថា មានរួមបញ្ចូលនូវអំពើរំលោភសេពសន្ថវៈ នៅក្នុងជីវិតអាពាហ៍ពិពាហ៍ទេ ហើយរឿងនេះបានក្លាយជាទម្លាប់ទូទៅមួយដែលយល់ថាករណីប្តីរំលោភប្រពន្ធគឺមិនអាចទៅរួចទេ។ ជាលទ្ធផលដែលបកស្រាយដោយករណីទាំង៣នេះ មានន័យថាប្តីតែងតែរួចខ្លួន។

ករណីមួយចំនួន ប្រសិនបើមានបណ្តឹងព្រហ្មទណ្ឌ និងបណ្តឹងលែងលះ បណ្តឹងព្រហ្មទណ្ឌគឺត្រូវបានប្រើសម្រាប់ធ្វើការចរចានៅក្នុងបណ្តឹងលែងលះគ្នា។

[១៩] មាត្រា៩ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ តម្រូវឱ្យ "អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត" ធ្វើអន្តរាគមន៍ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬបម្រុងនឹងកើតឡើង ហើយរាយការណ៍ទៅព្រះរាជអាជ្ញា។
[២០] មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បានចែងថាគ្រប់សកម្មភាពនៃអំពើរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ឆ្នាំទៅ១០ឆ្នាំ។

ឧទាហរណ៍ ក្នុងករណីមួយប្រពន្ធបានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌរឿងអំពើហិង្សាក្នុងគ្រួសារ និងបណ្តឹងរដ្ឋប្បវេណីដើម្បីសុំលែងលះនិងមើលថែកូន ក៏ដូចជាការផ្តល់អាហារកិច្ចដល់កូន។ ចៅក្រមនៃបណ្តឹងរដ្ឋប្បវេណីបានចេញសាលក្រមឱ្យលែងលះគ្នា និងយល់ព្រមឱ្យកូនទៅភាគីប្រពន្ធជាអ្នកចិញ្ចឹម និង តម្រូវឱ្យភាគីប្តីទទួលខុសត្រូវចំពោះការផ្តល់អាហារ កិច្ច ដល់កូនប៉ុន្តែករណីនេះធ្វើបាន លុះត្រាតែនាងយ ល់ព្រមដកពាក្យបណ្តឹងព្រហ្មទណ្ឌតែប៉ុណ្ណោះ។ វិសាលភាពនៃការចូលរួមរបស់ ចៅក្រមក្នុងការចរចានេះគឺគ្មានភាពច្បាស់លាស់ទេ ប៉ុន្តែគាត់គួរតែបានដឹងច្បាស់ពីដំណើរការនេះ។ ការចរចាពាក់ព័ន្ធនឹងបណ្តឹងព្រហ្មទណ្ឌ ក៏កើតមាននៅក្នុងករណីដែលប្តីប្រពន្ធគ្មានសំបុត្រអាពាហ៍ពិពាហ៍ដែរ។ មានករណីមួយដែលជនរងគ្រោះបានដា ក់ពាក្យបណ្តឹងព្រហ្មទណ្ឌ ប៉ុន្តែនាងសម្រេចដកពា ក្យបណ្តឹងវិញ បន្ទាប់ពីប្តីរបស់នាងយល់ព្រមរស់នៅបែកគ្នានិងឱ្យប្រាក់នាងចំនួន៥០០ដុល្លារ។

មានករណីជាច្រើន ដែលស្ត្រីមិនបានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ។ ពេលសម្រេចចិត្តរស់នៅបែកគ្នាពីប្តីអ្នកទាំងនោះ ចង់ធ្វើរឿងនេះឱ្យបានឆាប់តាមវិធីស្រួលបំផុតដែលអាចធ្វើទៅបាន។ ដំណើរការរឿងក្តីព្រហ្មទណ្ឌចំណាយពេលយូរ និងការប្រឹងប្រែងខ្លាំង ដែលភ្ជាប់អ្នកទាំងនោះ ទៅនឹងស្ថានភាពអវិជ្ជមានក្នុងអតីតកាលហើយអាចទំនងជាមិនទទួលបានផលអ្វីទៀត។ ដូច្នេះអ្នកទាំងនោះយល់ឃើញថា វានាំតែខាតពេលវេលា។ សម្រាប់ករណីផ្សេងទៀត ការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ គឺជាហានិភ័យ។ ដូចបានពិភាក្សាខាងលើ ពេលខ្លះស្ត្រីមានការភ័យខ្លាចថា ប្រសិនបើអ្នកទាំងនោះប្តឹងប្តីរបស់ពួកគាត់នោះប្តីនឹង ត្រឡប់មកសងសឹកវិញ។ នេះជាហេតុផលសមស្របមួយ ដែលមិនចម្លែកពេកទេសម្រាប់ប្តីដែលបានអនុវត្តទោសក្នុងពន្ធនាគារ រួចហើយត្រឡប់ទៅផ្ទះវិញភ្លាមៗ បន្ទាប់ពីត្រូវបានដោះលែងដើម្បីសងសឹកប្រពន្ធ។ មានករណីមួយ ដែលប្តីបានអនុវត្តទោសក្នុងពន្ធនាគារចំនួន៨ខែ ដោយសារការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ហើយគាត់បានត្រឡប់ទៅផ្ទះវិញភ្លាមៗ បន្ទាប់ពីត្រូវបានដោះលែង និងបានយកកាំបិតតាំងតោ ដេញកាប់ប្រពន្ធរបស់គាត់មុនពេលរត់គេចខ្លួន។ ករណីនេះកើតមានឡើងទោះបីជាតុលាការ បានចាត់វិធានការផ្លូវច្បាប់មួយចំនួនសម្រាប់ការពារជនរងគ្រោះក៏ដោយ។ ឧទាហរណ៍ យោងតាមច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ប្រសិនបើស្ត្រីដាក់ពាក្យបណ្តឹងប្រឆាំងនឹងប្តី ហើយប្តីរបស់នាងមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ តុលាការអាចចេញដីកាការពារ សម្រាប់អំឡុងពេលស៊ើបអង្កេតទៅលើករណីនោះ[21]។យោងតាមក្រមព្រហ្មទណ្ឌ តុលាការមានអំណាចក្នុងការចេញដីកាបង្គាប់ឱ្យដាក់ទណ្ឌកម្មផ្សេងៗ ក៏ដូចជាការផ្តន្ទាទោសឱ្យជាប់ឃុំ ហើយវិធានការទាំងនេះ ក៏មានរួមបញ្ចូលនូវការហាមឃាត់ជនល្មើស មិនឱ្យបង្ហាញខ្លួននៅក្នុងតំបន់មូលដ្ឋានផងដែរ[22]។ លើសពីនេះ ប្រសិនបើការផ្តន្ទាទោសត្រូវបានព្យួរ ដែលភាគច្រើនជាករណីអំពើហិង្សាក្នុងគ្រួសារ (មើលចំណុចបន្ទាប់) តុលាការមានអំណាចបង្គាប់ឱ្យហាមឃាត់ជននោះ មិនឱ្យបង្ហាញខ្លួននៅទីតាំងជាក់លាក់ណាមួយ[23] ដូច្នេះហើយ ជននោះមិនអាចនៅជិតមនុស្សពាក់ព័ន្ធក្នុងរឿងក្តី រួមទាំងជនរងគ្រោះផងដែរ[24]។ ទោះបីជាយ៉ាងណា លីកាដូ មិនបានឃើញអំណាចទាំងនេះត្រូវបានប្រើប្រាស់ នៅក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារនោះទេ។

ហេតុផលមួយទៀត ដែលនាំឱ្យបណ្តឹងព្រហ្មទណ្ឌមានតិចពាក់ព័ន្ធនឹងបណ្តឹងលែងលះគ្នាគឺ ស្ត្រីជាច្រើនហាក់ដូចជាប្តឹងលែងលះតែនៅពេលអ្នកទាំងនោះ គ្មានជម្រើសប៉ុណ្ណោះ ឧទាហរណ៍ដូចជានៅពេលដែលប្តីរបស់ពួកគាត់ចាកចេញទៅមានស្នេហាជាមួយនារីផ្សេងទៀត។ មានករណីមួយដែលប្តីតែងតែវាយធ្វើបាបប្រពន្ធ នៅពេលគាត់ស្រវឹង។ នាងមិនបានដាក់ពាក្យបណ្តឹងទេ ប៉ុន្តែក្រោយមកប្តីរបស់គាត់បានចាកចេញពីផ្ទះ និងចាប់ផ្តើមទំនាក់ទំនងស្នេហាជាមួយស្ត្រីផ្សេងម្នាក់ទៀត។ នាងបានរៀបអាពាហ៍ពិពាហ៍ស្របតាមច្បាប់ ដូច្នេះហើយ ប្រហែល១ឆ្នាំក្រោយមក នាងបានទៅតុលាការដើម្បីសុំសាលក្រមលែងលះគ្នា។ ក្នុងស្ថានភាពនេះ នគរបាលអាចទំនងជាមិនចាត់វិធានការទេ ដូច្នេះជនរងគ្រោះនឹងមិនទទួលបានផលអ្វីពីការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌនោះដែរ។

[21] មាត្រា២៣ (២) នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥។
[22] មាត្រា៥៣ (៥) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។
[23] មាត្រា១២០ (៩) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។
[24] មាត្រា១២០ (១២) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។




ស្ត្រីម្នាក់ត្រូវបានប្តីជា មនុស្សប្រមឹកវាយធ្វើបាបជាញឹកញាប់។ ភ្លាមៗបន្ទាប់ពីប្តីប្រើអំពើហិង្សាដោយដាល់លើផ្ទៃមុខនាងជាច្រើនដៃ បណ្តាលឱ្យជាំ និងហើមជាខ្លាំង នាងបានទាក់ទងទៅប៉ុស្តិ៍នគរបាលឃុំ ក្នុងមូលដ្ឋានឱ្យជួយដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ ប៉ុន្តែពួកគាត់បានបដិសេធក្នុងការចាត់វិធានការ។ បុគ្គលិកលីកាដូម្នាក់បានជួយជូននាងទៅប៉ុស្តិ៍នគរបាលស្រុក ប៉ុន្តែនគរបាលបានស្តីបន្ទោសឱ្យនាង អំពីការរាយការណ៍ករណីទៅកាន់ពួកគាត់ ដោយនិយាយថានាងគួរតែត្រឡប់ទៅជួបអាជ្ញាធរឃុំវិញ ហើយឱ្យអាជ្ញាធរនោះហៅប្តីរបស់នាងទៅផង ដើម្បីឱ្យប្តីប្រពន្ធចរចារកការផ្សះផ្សាគ្នាវិញ។ លីកាដូបានសរសេរពាក្យបណ្តឹងដោយផ្ទាល់ទៅកាន់ព្រះរាជអាជ្ញា ប៉ុន្តែនៅដំណាក់កាលនេះ ជនរងគ្រោះក៏បានផ្លាស់ប្តូរចិត្តពីការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ ដោយនិយាយថាធ្វើបែបនេះគ្មានប្រយោជន៍ទេ ហើយក៏សម្រេចចិត្តគ្រាន់តែរស់នៅបែកគ្នាជាមួយប្តីវិញ។

ច្រកចូលតុលាការខេត្ត

ក្នុងចំណោមករណីជាច្រើន ដែលលីកាដូយកមកធ្វើជាមូលដ្ឋាននៃការផលិតរបាយការណ៍នេះមាន៥៣ករណី (២៣%) បានបិទបញ្ចប់ដោយសវនាការព្រហ្មទណ្ឌ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារមិនបានចែងនូវបទបញ្ញត្តិស្តីពីការផ្តន្ទាទោសព្រហ្មទណ្ឌទេ ប៉ុន្តែមានចែងពីអំពើហិង្សាក្នុងគ្រួសារ ដែលមានចរិតជាបទល្មើសព្រហ្មទណ្ឌមានលក្ខណៈជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមកម្រិតធ្ងន់ ដែលគួរត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌ[២៥]។ នេះមានន័យថា នៅក្នុងទ្រឹស្តីមានបទចោទនិងទណ្ឌកម្មជាច្រើនដែលអាចធ្វើទៅបាន អាស្រ័យលើលក្ខណៈនៃអំពើហិង្សា។

ឧទាហរណ៍ នៅពេលអំពើហិង្សានៅក្នុងគ្រួសារបណ្តាលឱ្យជនរងគ្រោះស្លាប់ ករណីនេះតែងតែចាត់ការដោយសវនាការព្រហ្មទណ្ឌ ហើយជាទូទៅជនសង្ស័យនឹងត្រូវចោទពីបទឃាតកម្ម។ ក្នុងចំណោម៥៣ករណីខាងលើមាន១២ករណីជនរងគ្រោះបានស្លាប់។ ការផ្តន្ទាទោសក្នុងករណីទាំងនេះមានខុសៗគ្នា ប៉ុន្តែក្នុង នោះមាន៨ករណីដែលត្រូវបានផ្តន្ទាទោសត្រឹមត្រូវតាមទំហំនៃបទឃាតកម្ម គឺជាប់ពន្ធនាគារពី ១ ០ឆ្នាំ ទៅ ១៥ឆ្នាំ[២៦] ឬ បទឃាតកម្មមានស្ថានទម្ងន់ ទោ សដោយជាប់ពន្ធនាគា រពី ១៥ឆ្នាំ ទៅ ៣០ឆ្នាំ[២៧]។

ទោះបីជាយ៉ាងណាក៏ដោយ មានករណីដែលត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ តិចជាងរយៈពេលចែងនៅក្នុងច្បាប់។ មានករណី២ដែលការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមានរយៈពេលត្រឹមតែ៧ឆ្នាំប៉ុណ្ណោះ។ ក្នុងនោះមាន១ករណី ដែលការផ្តន្ទាទោសត្រូវបានកាត់បន្ថយឱ្យនៅរយៈពេលខ្លី ដោយសារជនល្មើសត្រូវបានវិនិច្ឆ័យថាមានវិបល្លាសស្មារតី[២៨]។ ចំណែកករណីផ្សេងទៀត ការកាត់បន្ថយរយៈពេលផ្តន្ទាទោសឱ្យនៅ ខ្លី មិនបានបញ្ជាក់មូលហេតុឱ្យបានច្បាស់ទេ។ករណីមួយទៀតជ ន ល្មើ ស បានចាក់ស្រោចសាំងលើប្រពន្ធនិងដុតខ្លួន នាង ប៉ុន្តែការផ្តន្ទាទោសមានរយៈពេលបួនឆ្នាំប៉ុណ្ណោះ។ ការផ្តន្ទាទោសនេះ មើលទៅហាក់ដូចជា មិ ន សមស្រប ទាល់ តែសោះ ដោយសារនេះជាភាពសាហាវឃោរឃៅនៃបទល្មើស និងគ្មានហេតុផលដែលត្រូវអនុគ្រោះ។ មា នករណីចុងក្រោយមួយដែលជនល្មើ ស បា នប្រើដំប ង វាយទៅលើម្តាយក្មេករហូតដល់ស្លា ប់ ខណៈពេលគាត់ព្យាយាមឃាត់ជននោះកុំឱ្យវាយ ប្រហារលើកូ នស្រីគាត់។ ដំបូងឡើយ ជនល្មើសត្រូវបានចោទពីបទប្រើអំពើហិង្សាដោយចេតនាបណ្តាលឱ្យជនរងគ្រោះស្លា ប់ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ឆ្នាំ ទៅ ១៥ឆ្នាំ ប៉ុន្តែក្រោយមកត្រូវបានប្តូរទៅចោទពីបទមនុស្សឃាត ដោ យអចេតនា នៅក្នុងសវនាការវិញ ដែលមានការ ផ្តន្ទាទោសពី ១ឆ្នាំ ទៅ៣ឆ្នាំ តែប៉ុណ្ណោះ។ ជនល្មើស ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ២ឆ្នាំ ប៉ុន្តែរយៈពេល ១៦ខែ ត្រូវបានព្យួរ ដូចនេះជនល្មើសត្រូវជាប់ពន្ធនាគាររយៈពេល ៨ខែ តែប៉ុណ្ណោះ។ ជាថ្មីម្តងទៀត ការផ្តន្ទាទោសនេះហាក់ដូចជា មិនសមស្របជាមួយនឹងស្ថានទម្ងន់ទោសទាល់តែសោះ។

ថ្វីបើច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារមិនបានបញ្ជាក់មាត្រានៅក្នុងក្រមព្រហ្មទណ្ឌ ដែលគួរយកទៅប្រើក្នុងករណីអំពើហិង្សាក្នុងគ្រួសារក៏ដោយ ប៉ុន្តែក្រមព្រហ្មទណ្ឌពិតជាមានមាត្រាដែលចែងច្បាស់ពីអំពើហិង្សាក្នុងគ្រួសារដូចជា មាត្រា២២២ចែងថា អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ។ ពេលមានការផ្តន្ទាទោសករណីនេះ តែងតែមានភាពមិនច្បាស់លាស់ថាតើ មាត្រានេះត្រូវបានប្រើប្រាស់ឬអត់ ប៉ុន្តែករណីភាគច្រើន ដែលមិនបណ្តាលឱ្យជនរងគ្រោះស្លាប់ ការផ្តន្ទាទោសដាក់ពន្ធនាគារគឺរយៈពេល៥ឆ្នាំ ឬតិចជាងនេះ។ ក្រៅពីនេះ គឺកម្រឃើញការផ្តន្ទាទោសមានភាពសមស្របណាស់។

ក្នុងចំណោម៥៣ករណី មាន៤០ករណីដែលបានជំនុំជម្រះដោយជនរងគ្រោះនៅរស់[២៩] ហើយជនល្មើសត្រូវបានផ្តន្ទាទោសនិងត្រូវអនុវត្តទោសជាប់ពន្ធនាគារ។ មាន ១ ២ ករណីដែលការផ្តន្ទាទោសដាក់ពន្ធនាគារគឺមានរយៈពេលតិចជាង២ឆ្នាំ ហើយក្នុងនោះមាន៥ករណីតិចជាង១ឆ្នាំតែប៉ុណ្ណោះ។ ក្នុងចំណោម១២ករណីនេះ មាន៤ករណីដែលបុគ្គលិកលីកាដូបានរាយការណ៍ថា ការផ្តន្ទាទោសគឺផ្អែកតាមមាត្រា២២២នៃក្រមព្រហ្មទណ្ឌ ដូចនេះមានន័យថាចៅក្រមហាក់ដូចជាមើលរំលង រយៈពេលផ្តន្ទាទោសចំពោះករណីទាំងនេះ។ ក្នុងករណីផ្សេងៗទៀត មាត្រានៅ

[២៥] មាត្រា១៩ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥។
[២៦] មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។
[២៧] មាត្រា២០២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។
[២៨] ករណីនេះត្រូវបានអនុញ្ញាតដោយមាត្រា៣១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។
[២៩] មាន៥ករណីផ្សេងទៀត ដែលត្រូវបានបិទបញ្ចប់ដោយជនរងគ្រោះស្លាប់ ប៉ុន្តែមិនបានជំនុំជម្រះទេ។ ក្នុងនោះមាន២ករណី ដែលជនល្មើសបានធ្វើអត្តឃាត ហើយករណី១ទៀត ជនល្មើសត្រូវបានកូនប្រុសរបស់ខ្លួនសម្លាប់ និងមាន១ករណីទៀត ដែលប្តីប្រពន្ធសម្លាប់គ្នាទៅវិញទៅមក

ក្នុងក្រមព្រហ្មទណ្ឌ ដែលបានយកទៅប្រើប្រាស់មិនសូវមានភាពច្បាស់លាស់ទេ ប៉ុន្តែលក្ខណៈនៃអំពើហិង្សាដែលបុគ្គលិកលីកាដូបានចងក្រងអាចបញ្ជាក់ថាការផ្តន្ទាទោសត្រូវបានអត់ឱនដោយមិនសមហេតុផលទេ។ ឧទាហរណ៍ មានករណីមួយ ដែលជនល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល៨ខែ បន្ទាប់ពីវាយដំជនរងគ្រោះឱ្យរងរបួសក្បាលយ៉ាងធ្ងន់ធ្ងរ។ មានករណីមួយទៀត ដែលជនល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ៧ខែ បន្ទាប់ពីយកបន្ទះឈើវាយប្រពន្ធរបស់គាត់ជាច្រើនដង។

ក្នុងចំណោម៤០ករណី មាន២៦ករណីដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ ប៉ុន្តែក្នុងនោះមាន១១ករណីដែលផ្នែកខ្លះនៃការផ្តន្ទាទោសត្រូវបានព្យួរទោស។ យោងតាមច្បាប់កម្ពុជា ការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលតិចជាង ឬស្មើ៥ឆ្នាំ អាចត្រូវបានព្យួរទោស ដរាបណាជនល្មើសមិនធ្លាប់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារក្នុងរយៈពេល៥ឆ្នាំចុងក្រោយ[៣០]។ ហេតុផលនៃការព្យួរទោសទាំងនេះមិនត្រូវបានដឹងនោះទេ ប៉ុន្តែជាលទ្ធផល ការផ្តន្ទាទោសដាក់ពន្ធនាគារមួយចំនួន គឺពិតជាមានរយៈពេលខ្លីមែនទែន ដោយទោសខ្លីជាងគេ គឺមានរយៈពេលត្រឹមតែ៥ខែប៉ុណ្ណោះ។ ករណីខ្លះ ការផ្តន្ទាទោសត្រូវបានកាត់បន្ថយត្រឹមរយៈពេលដែលជនល្មើស បានអនុវត្តទោស នៅក្នុងដំណាក់កាលឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ មានន័យថាជនល្មើសត្រូវបានដោះលែងមកវិញភ្លាមៗ បន្ទាប់ពីបញ្ចប់សវនាការ។ ផ្អែកតាមរយៈបទពិសោធន៍ការងាររបស់បុគ្គលិកលីកាដូ ជនរងគ្រោះមួយចំនួន បានត្អូញត្អែរថា ការព្យួរទោសអាចកើតមានឡើងបន្ទាប់ពីជនល្មើសបង់ប្រាក់ក្រោមតុ ដែលនេះអាចជាហេតុផលគួរឱ្យចាប់អារម្មណ៍មួយ ទោះបីជាយើងគ្មានភ័ស្តុតាងបញ្ជាក់លើករណីនេះក៏ដោយ។ ក្នុងករណីអំពើហិង្សាក្នុងគ្រួសារមួយចំនួន ការព្យួរទោសក៏អាចកើតមានឡើងដែរ នៅពេលជនរងគ្រោះស្នើសុំឱ្យមានការផ្តន្ទាទោសត្រឹមរយៈពេលខ្លី ដោយសារនាងគ្មានលទ្ធភាពរកប្រាក់ផ្គត់ផ្គង់ខ្លួនឯង និងកូនៗ ប្រសិនបើប្តីនាងត្រូវជាប់ឃុំក្នុងពន្ធនាគារ។

ក្នុងចំណោម៤០ករណី មាន២ករណី[៣១] ដែលជនរងគ្រោះនៅរស់ ប៉ុន្តែអំពើហិង្សាត្រូវបានចាត់ទុកថាធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនល្មើសពីបទប៉ុនប៉ងមនុស្សឃាត។ ការផ្តន្ទាទោសដាក់ពន្ធនាគារករណីទី១ គឺមានរយៈពេល១៨ឆ្នាំនិងករណីទី២គឺ១០ឆ្នាំ។ បទចោទហាក់ដូចជាសមស្របដោយសារករណីនេះ មានការប្រើកាំបិតតាំងតោដើម្បីកាប់ទៅលើជនរងគ្រោះ បណ្តាលឱ្យរងរបួសជាទម្ងន់ និងការប៉ុនប៉ងដុតផ្ទះចោលខណៈជនរងគ្រោះនៅខាងក្នុង។ទោះបីជាយ៉ាងណាការសម្រេចចោទប្រកាន់ពីបទប៉ុនប៉ងមនុស្សឃាត ហាក់ដូចជាអនុវត្តមិនបានត្រឹមត្រូវទេ។ ដូចបានពិភាក្សាខាងលើ ករណីដែលមានជាប់ពាក់ព័ន្ធនឹងអំពើហិង្សាធ្ងន់ធ្ងរ អាចបិទបញ្ចប់ដោយការផ្សះផ្សាគ្នា និងករណីផ្សេងៗទៀតដែលមើលទៅសមតែចោទប្រកាន់ពីបទប៉ុនប៉ងមនុស្សឃាត បែរជាបិទបញ្ចប់ដោយការផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេលខ្លី ទៅវិញ។ ឧទាហរណ៍ ក្នុងចំណោម៤០ករណីខាងលើ មាន១ករណីដែលជនល្មើស ព្យាយាមកាត់បំពង់ករបស់ប្រពន្ធ និងករណីមួយទៀតជនល្មើសបានបាញ់ជនរងគ្រោះ ប៉ុន្តែជនល្មើសទាំងពីរនាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ត្រឹមតែរយៈពេល៥ឆ្នាំប៉ុណ្ណោះ ដោយចោទប្រកាន់ពីបទប្រើអំពើហិង្សាលើសហព័ទ្ធ។

**ការផ្តន្ទាទោសដាក់ពន្ធនាគារនៃករណីអំពីហិង្សាក្នុងគ្រួសារ**




**— ការផ្តន្ទាទោសដាក់ពន្ធនាគារជាអតិបរមាក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ផ្អែកតាមក្រមព្រហ្មទណ្ឌ គឺរយៈពេល២៤ខែ**

[៣០] មាត្រា១០៦និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។
[៣១] ក្នុងនោះមាន១ករណីដែលបានជំនុំជម្រះ ប៉ុន្តែជនល្មើសត្រូវបានរកឃើញថាគ្មានទោស។

# សេចក្តីសន្និដ្ឋាន

រយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ លីកាដូបានឃ្លាំមើលលើ ករណីអំពើហិង្សាក្នុងគ្រួសាររាប់ពាន់ករណី។ ភាគច្រើននៃករណីទាំងនេះមានជាប់ពាក់ព័ន្ធនឹងស្ត្រីដែលរងគ្រោះជាច្រើនឆ្នាំដោយរងរបួសលើរូបរាងកាយ ការប៉ះទង្គិចផ្លូវចិត្ត និងភាពភ័យខ្លាចជាដើម។ ការសិក្សាស្រាវជ្រាវថ្មីៗនេះ ស្តីពី អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាបានបង្ហាញថា មានស្ត្រីតិចណាស់ ដែលបានរាយការណ៍ពីករណីអំពើ ហិង្សាក្នុងចំណោមស្ត្រីទាំងអស់ដែលកំពុងទ្រាំរស់នៅជាមួយអំពើហិង្សា ហើយនេះមានន័យថាមានស្ត្រីជាច្រើន ទៀតដែលកំពុងទ្រាំរងគ្រោះតែម្នាក់ឯង។

របាយការណ៍នេះផ្តោតសំខាន់លើស្ត្រីដែលបានជួបប្រទះអំពើហិង្សាក្នុងគ្រួសារ និងបានរាយការណ៍ពីករណីនោះ។ របាយការណ៍នេះក៏បង្ហាញថា រដ្ឋាភិបាលមិនទាន់បំពេញកាតព្វកិច្ចឱ្យបានម៉ត់ចត់ ដើម្បីការពារជនរងគ្រោះទាំងនោះ ដូច្នេះដំណោះស្រាយលើបញ្ហាអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា គឺនៅមិនសូវមានប្រសិទ្ធភាពទេ។ ដូចលទ្ធផលនៃករណីរបស់លីកាដូ បានបង្ហាញថា មានស្ត្រីជាច្រើន ដែលគ្មានជម្រើសអ្វីផ្សេង ក្រៅពីបន្តរស់នៅក្នុងស្ថានភាពហិង្សា ហើយជនល្មើសកម្រនឹងត្រូវបានផ្តន្ទាទោសណាស់។ ទោះបីមានការផ្តន្ទាទោសតាមច្បាប់ ប៉ុន្តែការផ្តន្ទាទោសនោះមិនគ្រប់គ្រាន់ ឬមិនសមស្រប។ ដោយសារហេតុផលទាំងនេះ ទើបស្ត្រីជាច្រើនយល់ថា ការស្វែងរកអន្តរាគមន៍ ទំនងជាមិនសូវទទួលបានផលអ្វីទេ ដូច្នេះក៏សុខចិត្តទ្រាំនៅស្ងៀមស្ងាត់។

មានកត្តាស្មុគស្មាញជាច្រើនដូចជា ការចាក់ឫសយ៉ាងជ្រៅនៃផ្នត់គំនិតសង្គម សេដ្ឋកិច្ច ជំនឿសាសនា និងកត្តាផ្លូវច្បាប់ជាដើម ដែលគួរត្រូវដោះស្រាយ ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន។ បញ្ហានេះ ទាមទារឱ្យរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចិត្តជាខ្លាំង និងផ្តល់ធនធានគ្រប់គ្រាន់ ហើយដំណើរការគួរតែដឹកនាំដោយមន្ត្រីដែលមានដំណែងខ្ពស់ៗ។ មន្ត្រីទាំងនោះគួរតែយល់ឱ្យបានច្បាស់ពីលក្ខណៈ ព្រហ្មទណ្ឌនៃអំពើហិង្សាក្នុងគ្រួសារ និងដោះស្រាយភាពខ្វះចន្លោះក្នុងច្បាប់ និងប្រព័ន្ធតុលាការក្នុងទំនួលខុសត្រូវឱ្យមានការគោរពច្បាប់ និងធានាថាអាជ្ញាធរដែលអនុវត្តច្បាប់ មានធនធានចាំបាច់គ្រប់គ្រាន់ដើម្បីអាចឱ្យអ្នកទាំងនោះបំពេញភារកិច្ច ប្រកបដោយប្រសិទ្ធិភាព។ ប្រសិនបើមិនមានការផ្លាស់ប្តូរទាំងនេះទេ អាជ្ញាធរអាចនឹងបន្តឱ្យមានភាពទន់ខ្សោយ មិនចំពោះតែស្ត្រីដែលស្វែងរកអន្តរាគមន៍ប៉ុណ្ណោះទេ ប៉ុន្តែនឹងប៉ះពាល់ដល់អ្នកដទៃជា ច្រើនទៀតដែលរងគ្រោះម្នាក់ឯង។




ការជិះកង់នៅថ្ងៃទិវាសិទ្ធិនារីអន្តរជាតិឆ្នាំ២០១៦ ដើម្បីអំពាវនាវឱ្យបញ្ឈប់ការប្រើអំពើហិង្សាលើស្ត្រីភេទ

## អនុសាសន៍

អំពើហិង្សាក្នុងគ្រួសារគឺជាបញ្ហាស្មុគស្មាញមួយដែលមានច្រើនរូបភាព។ ប៉ុន្តែរបាយការណ៍នេះផ្តោតសំខាន់លើចំណុចមួយចំនួនតែប៉ុណ្ណោះ ហើយអនុសាសន៍ខាងក្រោមនេះផ្ញើជូនអ្នកធ្វើការដោយផ្ទាល់លើការដោះស្រាយបញ្ហានានាដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ។ យើងខ្ញុំសង្ឃឹមថា៖

►►► មន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល ក៏ដូចជានគរបាលនិងតុលាការ នឹងថ្កោលទោសម្តងហើយម្តងទៀតទៅលើករណីអំពើហិង្សាក្នុងគ្រួសារ និងទទួលស្គាល់លក្ខណៈនៃអំពើហិង្សាក្នុងគ្រួសារថាជាបទល្មើសព្រហ្មទណ្ឌ។

►►► ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទដើម្បីផ្សព្វផ្សាយព័ត៌មានទៅសាធារណជនស្តីពីគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ។

►►► ផ្តល់ធនធានឱ្យបានគ្រប់គ្រាន់ដល់មន្ត្រីនគរបាលនិងអាជ្ញាធរមូលដ្ឋាន ដើម្បីអាចឱ្យអ្នកទាំងនោះមានលទ្ធភាពក្នុងការស៊ើបអង្កេតករណីនៃអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងអាចផ្តល់កិច្ចការពារ និងជួយគាំទ្រជនរងគ្រោះ ស្របតាមកាតព្វកិច្ចផ្លូវច្បាប់។

►►► បង្កើតបណ្តាញជម្រកសុវត្ថិភាពបណ្តោះអាសន្ននៅទូទាំងប្រទេសដែលឧបត្ថម្ភដោយរាជរដ្ឋាភិបាលសម្រាប់ជួយគាំទ្រស្ត្រីនិងកុមាររងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ដើម្បីឱ្យជនរងគ្រោះទាំងនោះអាចគេចចេញពីស្ថានភាពហិង្សា។

►►► បង្កើតកញ្ចប់ថវិកាពិសេសសម្រាប់ផ្គត់ផ្គង់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារដែលគ្មានលទ្ធភាពដំណើរការបណ្តឹងព្រហ្មទណ្ឌនិងបណ្តឹងលែងលះ ដើម្បីជួយគាំទ្រអ្នកទាំងនោះលើការចំណាយថ្លៃតុលាការ សោហ៊ុយធ្វើដំណើរ និងសំណងនៃថ្ងៃធ្វើការដែលបានខាតបង់។

►►► ធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដើម្បីនិរាករណ៍ចោលនូវបទបញ្ញត្តិដែលអនុញ្ញាត ឬលើកទឹកចិត្តឱ្យមានការផ្សះផ្សាករណីអំពើហិង្សាក្នុងគ្រួសារពីសំណាក់អាជ្ញាធរមូលដ្ឋាន ឬតុលាការ។

►►► ផ្តន្ទាទោសករណីទាំងអស់នៃអំពើហិង្សាក្នុងគ្រួសារ ដែលចាត់ចូលជាបទល្មើសព្រហ្មទណ្ឌ ដោយមិនត្រូវគិតពីឋានៈ ឥទ្ធិពលឬទ្រព្យសម្បត្តិរបស់ជនសង្ស័យ រួមបញ្ចូលទាំងករណីដែលជនរងគ្រោះមិនបានដាក់ពាក្យបណ្តឹង ឬបានដាក់ពាក្យបណ្តឹងប៉ុន្តែក្រោយមកបានដកពាក្យបណ្តឹងវិញហើយក៏ដោយ។

►►► ពង្រឹងការអនុវត្តបទបញ្ញត្តិមាត្រា៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌចំពោះមន្ត្រីនគរបាលដែលមិនចាត់វិធានការលើរឿងក្តីព្រហ្មទណ្ឌ ទោះបីជាជនរងគ្រោះបានដកពាក្យបណ្តឹងវិញ ឬមានការដោះស្រាយគ្នារវាងជនរងគ្រោះនិងជនសង្ស័យក៏ដោយ។

►►► រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់នគរបាល និងចៅក្រមស្តីពីការប្រើប្រាស់ដីកាការពារនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ និងទោសបន្ថែមផ្សេងៗទៀតនៅក្នុងក្រមព្រហ្មទណ្ឌ ព្រមទាំងផ្តល់ធនធានបន្ថែមទៀតដើម្បីអាចធានាថា បទបញ្ញត្តិទាំងនេះអាចអនុវត្តទៅបានប្រកបដោយប្រសិទ្ធិភាព។

►►► ធ្វើវិសោធនកម្មមាត្រា៣៥នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដើម្បីបញ្ជាក់ថាសកម្មភាពនៃអំពើហិង្សាត្រូវតែទទួលការផ្តន្ទាទោសយោងតាមបទបញ្ញត្តិពាក់ព័ន្ធទាំងអស់នៃក្រមព្រហ្មទណ្ឌ មិនត្រឹមតែមាត្រា២២២ប៉ុណ្ណោះទេ ដូចនេះការផ្តន្ទាទោសដាក់ពន្ធនាគារអតិបរមាគួរតែអាចយកមកអនុវត្ត។

►►► ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីធ្វើឱ្យច្បាស់ថាបទល្មើសនៃអំពើរំលោភសេពសន្ថវៈនៅក្នុងក្រមព្រហ្មទណ្ឌមានរួមបញ្ចូលនូវអំពើរំលោភសេពសន្ថវៈក្នុងជីវិតអាពាហ៍ពិពាហ៍ ដូច្នេះអំពើរំលោភសេពសន្ថវៈក្នុងជីវិតអាពាហ៍ពិពាហ៍មិនគួរត្រូវផ្តន្ទាទោសដោយប្រើប្រាស់បទបញ្ញត្តិស្តីពីអំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬអនីតិសង្វាសជននោះទេ។

www.licadho-cambodia.org